# សេចក្តីវិភាគលើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយឈរលើគោលការណ៍សិទ្ធិមនុស្ស

(អនុម័តដោយរដ្ឋសភានៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥)

រៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥

## សេចក្តីផ្តើម

សេចក្តីវិភាគនេះ ត្រូវបានរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)នៅកម្ពុជា ជាការរួមវិភាគទានមួយដល់កិច្ចពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ។ ការិយា ល័យOHCHR ផ្តល់សេចក្តីវិភាគនេះ ដោយយល់ឃើញថាច្បាប់នេះជាប់ជំពាក់ដោយផ្ទាល់លើលទ្ធភាពរបស់ អង្គការសង្គមស៊ីវិល (CSOs) ក្នុងការធ្វើសកម្មភាពការពារសិទ្ធិមនុស្ស និងក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ដូច្នេះហើយវាគឺជាការឆ្លុះបញ្ចាំងអំពីស្ថានភាពនៃការអភិវឌ្ឍប្រជាធិបតេយ្យរបស់កម្ពុជា។

ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានបញ្ជាក់បន្ថែមលើចំណុចនេះ ដោយការអះអាងថាសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម រួមជាមួយនឹងសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី គឺជាសមាសភាគដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ដោយសិទ្ធិសេរីភាពទាំងនេះ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងបុរស "ក្នុងការសម្តែងទស្សនៈនយោបាយរបស់ខ្លួន ចូលរួមក្នុងសកម្មភាពអក្សរសាស្ត្រ និងសិល្បៈ និងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចូលរួមក្នុងសកម្មភាពគោរពប្រតិបត្តិសាសនា ឬជំនឿដទៃផ្សេងទៀត បង្កើត និងចូលរួមក្នុងសកម្មភាពសហជីព និងសហករណ៍ និងធ្វើការជ្រើសរើសមេដឹកនាំ ដើម្បីតំណាងឲ្យផលប្រយោជន៍របស់ខ្លួន និងដាក់ឲ្យពួកគេទទួលខុសត្រូវ ឬគណនេយ្យភាព (សេចក្តីសម្រេចលេខ១៥/២១ បុព្វកថារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស)។

ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានរំលឹកផងដែរដល់ "រដ្ឋទាំងឡាយអំពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរព និងការពារយ៉ាងពេញលេញនូវសិទ្ធិបុគ្គលគ្រប់រូប ក្នុងការ.... ចូលរួមដោយសេរី ទាំងតាមរយៈប្រើអ៊ីនធើណិត និងមិនប្រើអ៊ីនធើណិត រាប់ទាំងក្នុងបរិបទនៃការបោះឆ្នោត ហើយរាប់ទាំងបុគ្គលដែលជាជនភាគតិច ឬដែលមានទស្សនៈ ឬជំនឿផ្សេងគ្នា អ្នកការពារសិទ្ធិមនុស្ស ប្រធានសហជីពកម្មករ និងអ្នកដទៃផ្សេងទៀត រាប់ទាំងទេសន្តរប្រវេសន៍ ដែលស្វែងរកការអនុវត្ត ឬការលើកកម្ពស់សិទ្ធិទាំងនេះ និងចាត់វាល់វិធានការចាំបាច់ ដើម្បីធានាថា ការរឹតបណ្តឹង

ណាមួយលើការអនុវត្តដោយសេរីនូវសិទ្ធិ...សេរីភាពក្នុងការបង្កើតសមាគមស្របតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ (សេចក្តីសម្រេចលេខ២១/៦ កថាខណ្ឌ១)។

ការិយាល័យ OHCHR បានត្រួតពិនិត្យឡើងវិញអំពីភាពស្របគ្នានៃសេចក្តីព្រាងនេះជាមួយច្បាប់ សិទ្ធិមនុស្សអន្តរជាតិដែលកំពុងអនុវត្ត។ ទន្ទឹមនឹងសេរីភាពក្នុងការបង្កើតសមាគម ត្រូវបានចែងក្នុងលិខិតុបករណ៍សិទ្ធិមនុស្សមួយចំនួនក្តី (សូមមើលឧបសម្ព័ន្ធ) ចំណុចស្នូលនៃសេចក្តីយោងនោះ គឺមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលកម្ពុជាជាភាគីមួយ ហើយមានខ្លឹមសារដូចខាងក្រោមនេះ៖

*១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកផ្សេង រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។*
*២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ នៅក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។*

ផ្អែកតាមមូលដ្ឋានគតិយុត្តថ្នាក់ជាតិ សិទ្ធិជាមូលដ្ឋាននេះត្រូវបានការពារ ដោយរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៤២ និងមាត្រា៣១ ដូចខាងក្រោម៖

**មាត្រា៤២**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់សង្គម។

**មាត្រា៣១** កថាខណ្ឌ១

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំង ឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។[1]

---

[1] ក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ០៩២/០០៣/២០០៧ ចុះថ្ងៃ១០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដោយតុលាការកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញបានគូសបញ្ជាក់យ៉ាងច្បាស់ថា ... សន្ធិសញ្ញាអន្តរជាតិទាំងអស់ជាផ្នែកនៃច្បាប់ជាតិ អនុវត្តនៅកម្ពុជា" រួមទាំងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និងច្បាប់ដទៃទៀតដែលកំពុងអនុវត្ត ក៏ដូចជា អនុសញ្ញាអន្តរជាតិទាំងអស់ ដែលកម្ពុជាបានទទួលស្គាល់។

សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ត្រូវបានបញ្ជាក់ឡើងវិញជាច្រើនលើកច្រើនសារ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ[2] ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប[3] អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម (ដែលចាប់ពីនេះតទៅ ហៅកាត់ថា (SRFAA)[4] តំណាងពិសេស អ.ស.ប ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស (ដែលចាប់ពីនេះតទៅហៅកាត់ថា (SRHRD)[5] និងគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប[6]។ អនុសាសន៍ស្តីពីកម្ពុជា ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលពិនិត្យរបាយការណ៍សកលតាមកាលកំណត់ (UPR) ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ហើយដែលរាជរដ្ឋាភិបាលបានទទួលយក[7] និងសេចក្តីសង្កេតសន្និដ្ឋានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប[8] ក៏ឆ្លុះបញ្ចាំងផងដែរអំពីសិទ្ធិជាមូលដ្ឋាននេះ។ គណៈកម្មាធិការសិទ្ធិមនុស្ស ជាពិសេស បានធ្វើការសន្និដ្ឋានថា "រដ្ឋភាគីគួរធានាថា ជនគ្រប់រូបអាចអនុវត្តដោយសេរីនូវសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការបញ្ចេញមតិ និងក្នុងការបង្កើតសមាគម ....ដើម្បីធ្វើកិច្ចការនេះ រដ្ឋភាគីគួរៈ ...(ឃ) ពិនិត្យឡើងវិញរាល់ច្បាប់ និង សេចក្តីព្រាងច្បាប់ទាំងឡាយដែលមានស្រាប់ រាប់ទាំងសេចក្តីព្រាងច្បាប់ស្តីពីបទឧក្រិដ្ឋតាមប្រព័ន្ធ បច្ចេកវិទ្យា និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជៀសវាងការប្រើប្រាស់ពាក្យពេចន៍ស្រពិចស្រពិល ឬមិនច្បាស់លាស់ និងការរឹតត្បិតជាទូទៅទូលំទូលាយ

---

[2] សេចក្តីសម្រេចរបស់មហាសន្និបាតលេខ៥៣) ១៤៤/A/RES/53/144, (1999និងលេខ ៦៤) ១៦៣/A/RES/64/163, (2009

[3] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ១៥/២១, លេខ២១/១៦/, និងលេខ២៤/៦ ស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម A/HRC/RES/15/21, A/HRC/RES/21/16, A/HRC/RES/.24/5

[4] របាយការណ៍របស់អ្នករាយការណ៍ពិសេស អប ស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី.ស. និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម)SRFAA ( A/HRC/ ១៣កថាខណ្ឌទី 20/27A/HRC/១៧និងទី ១៥កថាខណ្ឌទី 23/39 A/HRC/26/29 កថាខណ្ឌទី១៦ ដល់កថាខណ្ឌទី២១ A/HRC/29/25 កថាខណ្ឌទី២១។

[5] របាយការណ៍របស់អ្នករាយការណ៍ពិសេស អ ប.ស.ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស A/59/401, A/64/226, A/67/292 និង HRC/25/55

[6] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ១៥ (១៩៨៦) ស្តីពីតួនាទីរបស់ជនបរទេស ក្រោមកតិកាសញ្ញានេះសេចក្តីពន្យល់ទូទៅ , ២៣លេខ(១៩៩៤) ស្តីពីសិទ្ធិជនភាគតិច)២៥សេចក្តីពន្យល់ទូទៅលេខ ,១៩៩៦( ស្តីពីសិទ្ធិប្រជាពលរដ្ឋគ្រប់រូបក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត និងសិទ្ធិប្រើប្រាស់សេវាសាធារណៈ និងសេចក្តីពន្យល់ទូទៅលេខ៣៤(២០១១) ស្តីពីសេរីភាពក្នុងការបញ្ចេញមតិយោបល់សេចក្តី ,សង្កេតសន្និដ្ឋានស្តីពីកម្ពុជា (CCPR/C/KHM/CO/(2 ក្នុងចំណោមសេចក្តីសង្កេតសន្និដ្ឋានជាច្រើនទៀតរបស់គណៈកម្មាធិការសិទ្ធិមនុស្ស/១២២៦ឧបាស្រ័យលេខ ,២០០៣ រវាង Korneenko v. Belarus, ទស្សនៈអនុម័តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ឧបាស្រ័យ , លេខ១៣៨៣២០០៥/ រវាង Katsora et al. v. Belarus ,២០១០ខែតុលា ឆ្នាំ ២៥ទស្សនៈអនុម័តនៅថ្ងៃទី ,ឧបាស្រ័យលេខ១៩៩៣ ,២០១០/រវាង Mikhailovskaya and Volchek v. Belarus, ទស្សនៈអនុម័តនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ កថាខណ្ឌ៧/២១៦៥ឧបាស្រ័យលេខ ,៣.២០១២ ,រវាង Pinchuk v. Belarus ទស្សនៈអនុម័តនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ ក្នុងចំណោមសេចក្តីសម្រេចជាច្រើនរបស់គណៈកម្មាធិការសិទ្ធិមនុស្ស។

[7] របាយការណ៍របស់ក្រុមការងារពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (UPR) របស់កម្ពុជា ឆ្នាំ២០១៤ A/HRC/26/16 និងឧបសម្ព័ន្ធ១, ទស្សនៈស្តីពីការសន្និដ្ឋាន និងឬអនុសាសន៍ ការសន្យាដោយចិត្តស្ម័គ្រចិត្ត និងការឆ្លើយតបដែលបង្ហាញដោយរដ្ឋស្ថិតក្រោមការពិនិត្យរបាយការណ៍/, A/HRC//26/16ឧបសម្ព័ន្ធ១, អនុសាសន៍លេខ 118.19, 118.104, 118.106, 118.107, 118.110, 118.111, និងរបាយការណ៍របស់ក្រុមការងារពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់(UPR) របស់កម្ពុជា ឆ្នាំ២០០៩ A/HRC/13/4, 51 អនុសាសន៍លេខ៥១ និងអនុសាសន៍លេខ៥៦។

[8] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សលើរបាយការណ៍តាមកាលកំណត់ទីពីររបស់កម្ពុជា CCPR/C/KHM/CO/ខែមីនា ឆ្នាំ 2 ។២០១៥

ពេក ដើម្បីធានាថា ការរិតត្បិតមួយចំនួនលើការអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម ស្របតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងមាត្រា១៩(ចំណុច៣) និងមាត្រា២២ នៃកតិកាសញ្ញានេះ។˝

សេរីភាពក្នុងការបង្កើតសមាគមគឺជាសិទ្ធិរបស់មនុស្សគ្រប់រូបដោយមិនគិតពីអាយុ សញ្ជាតិ និន្នាការនយោបាយ ឬបទពិសោធពីអតីតកាលរបស់ខ្លួនឡើយ។ កតិកាសញ្ញា ICCPR ប្រមើលឃើញថា ការរឹតត្បិតមួយចំនួនអាចនឹងមាន ទៅលើការប្រើប្រាស់សេរីភាពក្នុងការបង្កើតសមាគមស្ថិតក្រោមកាលៈទេសៈមួយចំនួន ដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រា២២ នៃកតិកាសញ្ញានេះ។ បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប បន្ទុកភស្តុតាងធ្លាក់ទៅរដ្ឋភាគីត្រូវពន្យល់ពីហេតុផលដែលនាំឲ្យមានការដាក់ការរិតត្បិតចាំបាច់ឡើង។[9]

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ តម្រូវឲ្យមានភាពច្បាស់លាស់នៅក្នុងច្បាប់។ នៅក្នុងសេចក្តីពន្យល់លើកមុន ការិយាល័យ OHCHR បានលើកឡើងពីសេចក្តីត្រូវការភាពច្បាស់លាស់ ដើម្បីជាប្រយោជន៍ដល់អ្នកស្នើសុំចុះបញ្ជី សម្រាប់មន្ត្រីរដ្ឋាភិបាលដែលមានការទទួលខុសត្រូវក្រោមច្បាប់នេះ និងសម្រាប់តុលាការដែលត្រូវបានប្រគល់ភារកិច្ចឲ្យពង្រឹងអនុវត្ត និងបកស្រាយច្បាប់។ អ្នកចូលរួមជាច្រើននៅក្នុងសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់លើកទីបួននៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ បានគូសបញ្ជាក់ពីលទ្ធភាពបកស្រាយដែលអាចធ្វើបាន ក្រោមសេចក្តីព្រាងច្បាប់ដែលបានចែកផ្សាយកន្លងមក ចំណុចមួយដែលភាគច្រើននៅតែមានសុពលភាពនោះឡើយ ទាក់ទងនឹងសេចក្តីព្រាងច្បាប់នេះ និងជាប្រធានបទមួយដែលកំពុងកើតមាននៅក្នុងសេចក្តីផ្តល់មតិដែលបានបង្ហាញនៅទីនេះ។

ប្រធានបទធំទីពីរ ដែលបាននិងកំពុងកើតឡើង គឺបញ្ហាទាក់ទងនឹងប្រព័ន្ធចុះបញ្ជី ដែលបានសំគាល់ឃើញមាននៅក្នុងសេចក្តីព្រាងច្បាប់នេះ។ យន្តការសិទ្ធិមនុស្សអន្តរជាតិ យល់ឃើញថា សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិឯកជនរបស់អង្គការសង្គមស៊ីវិល ត្រូវបានការពារប្រសើរឡើង តាមរយៈប្រព័ន្ធនៃការជូនដំណឹងដោយស្ម័គ្រចិត្ត ដែលការិយាល័យ OHCHR សូមជំរុញលើកទឹកចិត្ត។ ប្រព័ន្ធចុះបញ្ជីជាកម្មវត្ថុនៃការបន្ត នឹងមិនត្រឹមតែបង្កើតបរិយាកាសរឹតត្បិតបន្ថែមទៀតសម្រាប់សង្គមស៊ីវិល ជាពិសេសសម្រាប់អង្គការសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏អាចបង្កើតផងដែរ នូវបន្ទុកការងារធ្ងន់ធ្ងរថ្មីមួយទៀត សម្រាប់ក្រសួងការបរទេស និងក្រសួងមហាផ្ទៃ ក្នុងការត្រួតពិនិត្យ។ ការនេះ មិនធ្វើឲ្យថយចុះនូវកង្វល់ស្របច្បាប់អំពីការប្រយុទ្ធ

[9] សូមអានសេចក្តីសម្រេចនៅជើងទំព័រលេខ៧។

ប្រឆាំងនឹងបទល្មើស រាប់ទាំងនៅពេលដែលក្រុមសង្គមស៊ីវិល អាចនឹងចូលរួម។ ដូចបានឆ្លុះបញ្ចាំង នៅក្នុងសេចក្តីព្រាងច្បាប់នេះ (មាត្រា៣៦) ច្បាប់ព្រហ្មទណ្ឌដែលមានស្រាប់ គឺជាយានមួយសមស្របដើម្បីឆ្លើយតបនឹងកង្វល់ទាំងនេះ ហើយក៏បានអនុវត្តរួចហើយចំពោះបុគ្គល ឬអង្គការណាមួយដែលមានពិរុទ្ធភាពក្នុងអំពើល្មើសទាំងនេះ។

ភាពស្មុគស្មាញនៃផលប៉ះពាល់ជាច្រើននៃច្បាប់សម្រាប់បរិស្ថានសិទ្ធិមនុស្សនៅកម្ពុជានឹងបានលើកមកធ្វើជាហេតុផលសមស្រប សម្រាប់ការពិភាក្សា និងការពិគ្រោះយោបល់ស៊ីជម្រៅច្រើនថែមទៀត ដែលគួរតែបានធ្វើរហូតមកទល់ពេលនេះ។ នៅក្នុងសេចក្តីសម្រេចលេខ២២/៦ របស់ខ្លួន ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប បានគូសបញ្ជាក់ថា "ការរួមវិភាគទានដ៏មានតម្លៃរបស់ស្ថាប័នជាតិសិទ្ធិមនុស្ស សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងការផ្តល់មតិដល់រដ្ឋនានា អំពីផលប៉ះពាល់ដែលអាចមាននៃសេចក្តីព្រាងច្បាប់ នៅពេលដែលច្បាប់មួយត្រូវបានរៀបចំធ្វើ ឬពិនិត្យឡើងវិញ ដើម្បីធានាថា ច្បាប់នោះស្របទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ"[10]។ សូម្បីតែស្ថិតនៅក្នុងដំណាក់កាលផ្តាច់ព្រ័តនេះក្តី *ការិយាល័យ OHCHR សូមស្នើឲ្យមានការសើរើពិនិត្យឡើងវិញជាទូទៅ និងជាដំកំភួនចំពោះច្បាប់នេះ ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលបានលើកឡើង នៅក្នុងការវិភាគនេះ។*

សេចក្តីវិភាគនេះ ត្រូវបានរៀបចំឡើងផ្អែកលើអត្ថបទផ្លូវការនៃច្បាប់ដែលការិយាល័យ OHCHR បានទទួលពីរដ្ឋសភានៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ និងសំណៅកែសំរួលនៃច្បាប់នេះ ទទួលបានពីរដ្ឋសភានៅថ្ងៃទី១០ ខែកក្កដា ក៏ដូចជា អត្ថបទបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនៃច្បាប់នេះ ដោយការិយាល័យ OHCHR។

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១៖**

ច្បាប់នេះ មានគោលបំណងធានាការពារសិទ្ធិសេរីភាព ក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាល ជាមួយអាជ្ញាធរសាធារណៈ។

[10] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ២២ ២០១៣ស្តីពីការការពារអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ ៦/A/HRC/RES/១៧កថាខណ្ឌទី 22/6។

**អនុសាសន៍៖** *ការិយាល័យ OHCHR ស្វាគមន៍គោលបំណងដាក់លាក់នៅក្នុងមាត្រា១ ដែលចែងថា "ច្បាប់នេះ មានគោលបំណងធានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់..." ការិយាល័យ OHCHR ស្វាគមន៍ផងដែរ ចំពោះស្មារតីនៃ "កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ" រវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរ ដែលច្បាប់នេះមានគោលបំណងលើកកម្ពស់។ វានឹងមានប្រយោជន៍សម្រាប់ច្បាប់នេះ ដើម្បីកំណត់វិធីដាក់លាក់មួយចំនួន ដែលសេរីភាពនេះនឹងត្រូវបានរក្សាការពារនិងរបៀបដែលភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការនឹងត្រូវបានលើកកម្ពស់។ លើសពីនេះទៀត មានការកត់សម្គាល់ឃើញថាសេចក្តីព្រាងច្បាប់នេះ មិនត្រឹមតែជានីតិវិធីសម្រាប់ការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួនផងដែរ។*

*ការិយាល័យ OHCHR ស្នើសុំលុបពាក្យ "ការបង្កើត" ហើយស្នើរៀបចំសម្រួលពាក្យពេចន៍ជម្រើសដូចខាងក្រោមនេះ ដើម្បីបញ្ជាក់ឲ្យច្បាស់ថា អនុលោមតាមរដ្ឋធម្មនុញ្ញ ការការពារសេរីភាពក្នុងការបង្កើតសមាគម គឺជាគោលដៅចម្បងនៃសេចក្តីព្រាងច្បាប់នេះ៖ "ច្បាប់នេះ មានគោលបំណងធានាការពារសិទ្ធិអនុវត្តសេរីភាពរបស់សមាគមនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ក៏ដូចជាផលប្រយោជន៍សាធារណៈ។ ច្បាប់នេះ មានគោលបំណងផងដែរ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការនិងភាពជាដៃគូរវាងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល (ម្ខាង) និងអាជ្ញាធរសាធារណៈ(ម្ខាងទៀត)។*

**មាត្រា២៖**

ច្បាប់នេះ មានគោលដៅកំណត់បែបបទទទួលស្គាល់តាមផ្លូវច្បាប់ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកំណត់ទំនាក់ទំនងរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជា។

**អនុសាសន៍៖** *ពាក្យពេចន៍នៅក្នុងមាត្រា១ ចែងថា ច្បាប់នេះ "មានគោលបំណង..." ហើយ*

*ដើម្បីឲ្យរឹតតែច្បាស់ថែមទៀត គួរតែសរសេរថា "គោលបំណងនៃច្បាប់នេះគឺ....." នៅក្នុងមាត្រា២ ទំនងជាយោងទៅគោលដៅទាំងពីរនៃច្បាប់នេះ។ មូលហេតុសម្រាប់រូបមន្តផ្សេងគ្នានេះ គឺមិនច្បាស់លាស់។ ប្រសិនជាការរៀបចំឡើងវិញនៃមាត្រា១ ត្រូវបានទទួលយក (សូមមើលសេចក្តីផ្តល់មតិរបស់ការិយាល័យ OHCHR លើមាត្រា១) មាត្រា២ អាចត្រូវបានធ្វើវិសោធនកម្មទៅជា "ច្បាប់នេះកំណត់បែបបទដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចទទួលបានការទទួលស្គាល់តាមផ្លូវច្បាប់ និងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។"*

**មាត្រា៣៖**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាលើកលែងតែមានបទប្បញ្ញត្តិច្បាប់ដោយឡែកដែលចែងផ្សេងពីនេះ។

**<u>អនុសាសន៍៖</u>**

*<u>អង្គការនានាដែលមានមូលដ្ឋាននៅសហគមន៍៖</u> ការិយាល័យ OHCHR យល់ពីគោលបំណងរបស់មាត្រា៣ ដាក់អង្គការនានាដែលមានមូលដ្ឋាននៅសហគមន៍ ឲ្យស្ថិតនៅក្រៅវិសាលភាពអនុវត្តនៃច្បាប់នេះ ដែលការិយាល័យ OHCHR សូមស្វាគមន៍។ គោលការណ៍ណែនាំទូទៅ ក្នុងស្មារតីនៃរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ (ជាពិសេសកតិកាសញ្ញា ICCPR មាត្រា២២) នោះគឺការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនគួរជាកាតព្វកិច្ចឡើយ ផ្ទុយទៅវិញ គួរតែជម្រុញ តាមរយៈការលើកទឹកចិត្តសមស្រប ដូចជាពន្ធ និងអត្ថប្រយោជន៍ស្របច្បាប់ដទៃផ្សេងទៀត។ តំណាងពិសេស អ.ស.ប ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស(SRHRD) នេះបានគូសបញ្ជាក់ជាថ្មីអំពីទស្សនៈមួយចំនួននៅក្នុងរបាយការណ៍របស់លោកស្រីដាក់ជូនមហាសន្និបាត។[11]*

***ការិយាល័យ OHCHR គាំទ្រដល់ទស្សនៈដែលថា ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនគួរជាកាតព្វកិច្ចឡើយ។***

*<u>ទំនាក់ទំនងគ្នាជាមួយក្រមរដ្ឋប្បវេណី៖</u> ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងច្បាប់ឆ្នាំ២០១១*

[11] A/)៨២កថាខណ្ឌទី 59/401ក (ខ)និង (A/និង ៥៩កថាខណ្ឌទី 64/226A/និងទី ៤២កថាខណ្ឌទី 67/292៤៣។

*ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ច្បាប់ទាំងពីរនេះ មានបទប្បញ្ញត្តិដែលចែងអំពីការបង្កើត និងប្រតិបត្តិការរបស់នីតិបុគ្គលមិនយកកម្រៃ រាប់ទាំងមូលនិធិ[12] ដែលជាស្នូលនៃច្បាប់នេះ។ លក្ខណៈត្រួតស៊ីគ្នានៃច្បាប់ទាំងនេះ ទាក់ទងនឹងការកំណត់វិសាលភាពអនុវត្ត និងវិសាលភាពនៃអញ្ញត្រកម្ម ដែលមានចែងក្នុងមាត្រានេះ។*

**មាត្រា៤៖** វាក្យសព្ទ ដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

- សមាគមក្នុងស្រុក សំដៅដល់អង្គការសមាជិកភាព ដែលត្រូវបានបង្កើតឡើង ក្រោមច្បាប់របស់កម្ពុជា ដោយរូបវន្តបុគ្គលឬ/និងនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួន ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា។
- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សំដៅដល់អង្គការមិនមែនសមាជិកភាព រួមទាំងមូលនិធិ ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជា ដោយរូបវន្តបុគ្គលឬ/និងនីតិបុគ្គល ក្នុងគោលបំណងផ្តល់មូលនិធិ ឬសេវាកម្មលើវិស័យមួយឬច្រើន ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា។
- សមាគមបរទេស ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស សំដៅដល់អង្គការស្របច្បាប់ដែលបង្កើតឡើងនៅក្រៅប្រទេស ក្នុងគោលបំណងធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ។
- សមាគម សំដៅដល់សមាគមក្នុងស្រុក និងសមាគមបរទេស។
- អង្គការមិនមែនរដ្ឋាភិបាល សំដៅដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។

**<u>អនុសាសន៍៖</u>**

*<u>អង្គការនានាដែលមានមូលដ្ឋាននៅសហគមន៍៖</u> ការិយាល័យ OHCHR ស្វាគមន៍ការដាក់អង្គការនានាដែលមានមូលដ្ឋាននៅសហគមន៍ ឲ្យស្ថិតនៅក្រៅបញ្ជីនេះ។ ទោះជាដូច្នេះក្តី និយមន័យមិនច្បាស់លាស់នៃ "សមាគមក្នុងស្រុក" និង "អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក" អាចត្រូវបានធ្វើការបកស្រាយ ដើម្បីអង្គការដែលមានមូលដ្ឋាននៅសហគមន៍ ដែលអាចនាំឲ្យមានការតម្រូវឲ្យចុះបញ្ជី និងលក្ខខណ្ឌតម្រូវឲ្យធ្វើរបាយការណ៍ ដែលសមាគមភាគច្រើនមិនអាចធ្វើបាន។*

---

[12] សូមអានមាត្រា៤៦, ៤៨, ៤៩, ៥០, ៥១, ៥២, ៥៣ និងមាត្រា៥៤ នៃក្រមរដ្ឋប្បវេណី និងមាត្រា១៨, ១៩, ២០, ២១, ២២, ២៤ និងមាត្រា២៥ នៃច្បាប់ឆ្នាំ២០១១ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

**ការិយាល័យ OHCHR បានផ្តល់អនុសាសន៍ថា និយមន័យនេះ រួមបញ្ចូលធាតុផ្សំដែលញែកសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដាច់ចេញពីអង្គការដែលមានមូលដ្ឋាននៅសហគមន៍។**

*ភាពខុសគ្នារវាង "សមាគម" និង "អង្គការមិនមែនរដ្ឋាភិបាល"៖ ច្បាប់នេះបង្ហាញពីភាពខុសគ្នារវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហេតុផលអំពីភាពខុសគ្នានេះ មិនច្បាស់លាស់ទេ។ បើមើលលើទិដ្ឋភាពច្បាប់ អង្គការទាំងពីរនេះ គឺស្ថិតនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ[13] និងក្រោមច្បាប់រដ្ឋធម្មនុញ្ញក្នុងស្រុក គឺមិនមានភាពខុសគ្នានោះទេ៖ អង្គការទាំងពីរនេះ គឺជា "សមាគម"។*

**ការិយាល័យ OHCHR ផ្តល់អនុសាសន៍ឲ្យដកចេញនូវភាពខុសគ្នារវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហើយរក្សាទុកត្រឹមតែពាក្យ "សមាគម" ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ។**

*ផលប្រយោជន៍សាធារណៈ៖ ពាក្យ "ផលប្រយោជន៍សាធារណៈ" និយមន័យនៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនមានចែងសេចក្តីលំអិតបន្ថែម។ ភាពស្រពិចស្រពិលនេះ នាំមកនូវក្តីកង្វល់អំពីថាតើអ្នកណាជាអ្នកកំណត់ថា អ្វីជាផលប្រយោជន៍សាធារណៈ ឬអ្វីមិនមែនជាផលប្រយោជន៍សាធារណៈ តើផ្អែកលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ហើយការអនុវត្តបំពានលើការហាមប្រាម ធ្វើឡើងផ្អែកលើមូលហេតុនៃ "ផលប្រយោជន៍សាធារណៈ" អាចត្រូវបានបង្ការទប់ស្កាត់ ឬដោះស្រាយយ៉ាងដូចម្តេច។*

*យោងតាមមាត្រា២២ កថាខណ្ឌទី២ នៃកតិកាសញ្ញា ICCPR ការរឹតត្បិតណាមួយមានន័យថាជាការកម្រិតសិទ្ធិចូលរួមសមាគមដោយសេរី រាប់ទាំងផ្អែកលើហេតុផល "សណ្តាប់ធ្នាប់ ឬសីលធម៌ ឬសន្តិសុខសាធារណៈ" ត្រូវបំពេញបន្ថែមលក្ខខណ្ឌដូចខាងក្រោមនេះ៖ (ក) ត្រូវកំណត់ដោយច្បាប់ (ខ)អាចរឹតត្បិតសម្រាប់តែគោលដៅមួយក្នុងចំណោមគោលដៅទាំង ឡាយដែលមានចែងក្នុងកថាខណ្ឌទី២ និង(គ) ដែលចាំបាច់ក្នុងសង្គមប្រជាធិប*

---

[13] "សមាគម" សំដៅដល់ក្រុមមនុស្ស ឬនីតិបុគ្គល រួមគ្នាធ្វើសកម្មភាព សម្តែងមតិ លើកកម្ពស់ បន្តអនុវត្ត ឬការពារវិស័យនៃផលប្រយោជន៍រួមអ្វីមួយ។" សូមអាន A/HRC/20/27, កថាខណ្ឌទី៥១។

*តេយ្យ ដើម្បីសម្រេចគោលបំណងមួយនៃគោលបំណងទាំងនោះ។ យុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប បញ្ជាក់ច្បាស់អំពីសញ្ញាណនៃ "សង្គមប្រជាធិបតេយ្យ" ដោយបញ្ជាក់ថា "អត្ថិភាព និងប្រតិបត្តិការរបស់សមាគម រាប់ទាំងអង្គការទាំងឡាយដែលលើកកម្ពស់គំនិតដោយសន្តិវិធី មិនចាំបាច់ទាល់តែមានការគាំទ្រពីរដ្ឋាភិបាល ឬប្រជាពលរដ្ឋភាគច្រើនឡើយ គឺជាខ្ទឹម ឬជាស្នូលនៃសង្គមប្រជាធិបតេយ្យ។ ការគ្រាន់តែមាន អត្ថិភាពនៃការបង្ហាញពីគោលដៅ នៃការកម្រិតកំណត់សិទ្ធិសេរីភាពរបស់សមាគមប៉ុណ្ណឹង គឺមិនគ្រប់គ្រាន់ឡើយ។ រដ្ឋភាគីត្រូវតែបង្ហាញទៀតថា ការហាមប្រាមសមាគមមួយ គឺជាការចាំបាច់ ដើម្បីបញ្ចៀសការគំរាមកំហែងមួយពិតប្រាកដ និងមិនមែនជាការគំរាមកំហែងជាសម្មតិកម្មដល់សន្តិសុខជាតិ ឬសណ្ដាប់ធ្នាប់ប្រជាធិបតេយ្យដែលថា វិធានការមិនសូវតឹងតែង គឺមិនគ្រប់គ្រាន់ដើម្បីសម្រេចគោលបំណងដូចគ្នានេះ ហើយថាការរឹតត្បិតគឺមានលក្ខណៈសមាមាត្រទៅនឹងផលប្រយោជន៍ដែលត្រូវការពារ"។[14]*

**ការិយាល័យ OHCHR ស្នើដាក់បញ្ចូលបញ្ជីទូលំទូលាយមួយអំពីការលើកទឹកចិត្តដែលគ្របដណ្ដប់ដោយពាក្យដែលអាចនឹងមានប្រយោជន៍ ថាជាការលើកលែងមួយជាក់លាក់ចំពោះសកម្មភាពទាក់ទងនឹងសិទ្ធិមនុស្ស ចេញពីការរឹតត្បិតទាំងនេះ។**

*ម្យ៉ាងវិញទៀត និយមន័យនៅក្នុងសេចក្ដីព្រាងច្បាប់នេះ មិនបានបញ្ជាក់ច្បាស់ថាតើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានបង្កើតឡើងនៅកម្ពុជា ដោយអង្គភាពអន្តរជាតិមួយ នឹងត្រូវចាត់ទុកថាជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬបរទេសនោះទេ។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ទាំងពីរនេះ ជាញឹកញាប់ ត្រូវបានបង្កើតឡើងនៅប្រទេសក្រៅ ហើយបន្ទាប់មកមានជំពូក ឬផ្នែកជាតិ បានចុះបញ្ជីនៅថ្នាក់ជាតិ ជានីតិបុគ្គលជាតិ។*

**ការិយាល័យ OHCHR ស្នើសុំឲ្យមានការពន្យល់បំភ្លឺអំពីចំណុចនេះ។**

---

[14] ឧបាស្រ័យលេខ១៩៩៣/២០១០, រវាង Mikhailovskaya and Volchek v. Belarus ទស្សនៈអនុម័តនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ កថាខណ្ឌទី៧.៣។ សូមអានឧបាស្រ័យលេខ១២៧៤/២០០៤, រវាង Korneenko v. Belarus។ ទស្សនៈអនុម័តនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦ កថាខណ្ឌទី៧ ២.១១១៩លេខ ៣.៧និងកថាខណ្ឌទី/២០០២ ,រវាង Jeong-Eun Lee v. Republic of Korea ទស្សនៈអនុម័តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌទី៧២.; ឧបាស្រ័យលេខ១២៩៦/២០០៤, រវាង Belyatsky et al. v. Belarus ទស្សនៈអនុម័តនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។ សូមអានសេចក្ដីពន្យល់ទូទៅលេខ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស អ ប ស្ដីពីសេរីភាពក្នុងការបញ្ចេញមតិនិងយោបល់.ស.CCPR/C/GC/ 34កថាខណ្ឌទី៣៤។

# ជំពូកទី២
# ការបង្កើត និងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

**មាត្រា៥៖**

ការបង្កើតសមាគមក្នុងស្រុកតម្រូវឲ្យមានសមាជិកស្ថាបនិកដែលជារូបវន្តបុគ្គលចំនួន យ៉ាងតិច ៣(បី)រូប ដែលមានអាយុគ្រប់ ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ។

ការបង្កើតអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក តម្រូវឲ្យមានសមាជិកស្ថាបនិក ដែលជារូបវន្តបុគ្គលសញ្ជាតិខ្មែរចំនួនយ៉ាងតិច ៣(បី)រូប ដែលម្នាក់ៗមានអាយុគ្រប់ ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ។

**អនុសាសន៍**

*អាយុអប្បបរមានៃសមាជិកស្ថាបនិក៖ លក្ខខណ្ឌតម្រូវនេះអាចនឹងរិតត្បិតលទ្ធភាពរបស់អនីតិជនពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលអាចផ្ទុយទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC) ដែលកម្ពុជាគឺជារដ្ឋភាគី។ កម្ពុជាបានយល់ព្រមក្រោមមាត្រា១៥ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC) "ទទួលស្គាល់សិទ្ធិកុមារមានសេរីភាពខាងសមាគម និងមានសេរីភាពជួបប្រជុំដោយសន្តិវិធី" ដែលជាការរិតត្បិតក្រោមកាលៈទេសៈដូចគ្នា ដូចដែលមានចែងក្នុងមាត្រា២២ កថាខណ្ឌទី២ នៃកតិកាសញ្ញា ICCPR។ ដូច្នេះ លក្ខខណ្ឌតម្រូវនេះ មិនស្រប ទៅនឹងមាត្រា៣១ និងមាត្រា៤៨ នៃរដ្ឋធម្មនុញ្ញទេ សូមអានរួមគ្នាជាមួយមាត្រា១៥ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ(CRC)។ មាត្រា៥ និងមាត្រា១១ មិនស្របគ្នាទេ ព្រោះថា មាត្រា៥ មិនអនុញ្ញាតឲ្យរូបវន្តបុគ្គលដែលមានអាយុក្រោម១៨ (ដប់ប្រាំបី)ឆ្នាំ ធ្វើជាសមាជិកស្ថាបនិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឡើយ ចំណែកមាត្រា១១ វិញ ចែងថា លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់អនីតិជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។*

*ការិយាល័យOHCHR ស្នើសុំឲ្យដកចេញនូវលក្ខខណ្ឌតម្រូវអំពីអាយុអប្បបរមាក្នុងមាត្រា៥ ដើម្បីធានាការពារសិទ្ធិក្រោមច្បាប់នេះ និងមិនត្រូវស្ថិតក្រោមលិខិតបទដ្ឋានគតិយុត្តនៅថ្នាក់ក្រោមជាតិឡើយ។*

*លក្ខខណ្ឌតម្រូវសញ្ជាតិខ្មែរ ដើម្បីក្លាយជាសមាជិកស្ថាបនិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក៖* យោងតាមមាត្រា២២ នៃកតិកាសញ្ញា ICCPR បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការបង្កើតសមាគម។ មាត្រា២ កថាខណ្ឌទី១ នៃកតិកាសញ្ញា ICCPR ចែងថា កតិកាសញ្ញានេះ អនុវត្តចំពោះបុគ្គលគ្រប់រូប "នៅក្នុងដែនដីរបស់ខ្លួន" (នៃរដ្ឋភាគីមួយ) និង "ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន"។ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប បានបញ្ជាក់ច្បាស់ថា "ជាទូទៅ សិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញានេះ ត្រូវយកមកអនុវត្តចំពោះបុគ្គលគ្រប់រូប [... ] ដោយមិនគិតពីសញ្ជាតិ ឬភាពគ្មានរដ្ឋរបស់ពួកគេឡើយ"។[15] ការផាត់ចេញនូវបុគ្គលដែលមិនមានសញ្ជាតិខ្មែរ អាចនឹងបដិសេធសិទ្ធិនេះដល់ជនភៀសខ្លួន បុគ្គលគ្មានរដ្ឋ ទេសន្តរប្រវេសន៍ រាប់ទាំងជនបរទេសដែលស្នាក់នៅស្របច្បាប់ កម្មករដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងពួកធុរកិច្ចបរទេសជាដើម។ លក្ខខណ្ឌតម្រូវសញ្ជាតិនេះ អាចផ្ទុយទៅនឹងមាត្រា២២ កថាខណ្ឌទី១ នៃកតិកាសញ្ញា ICCPR ក៏ដូចជាមាត្រា១៥ នៃអនុសញ្ញាពាក់ព័ន្ធឋានៈជនភៀសខ្លួន។

***ការិយាល័យ OHCHR ស្នើឲ្យដកលក្ខខណ្ឌតម្រូវសញ្ជាតិនេះចេញ។***

**មាត្រា៦៖**

សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដោយបំពេញសំណុំលិខិតដូចខាងក្រោម៖

១. ពាក្យសុំចុះបញ្ជីចំនួន ២(ពីរ)ច្បាប់

២. លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្ដាលរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីមេឃុំ ឬចៅសង្កាត់ចំនួន ១(មួយ)ច្បាប់

៣. ជីវប្រវត្តិរបស់ស្ថាបនិកម្នាក់ៗមានបិទរូបថតបច្ចុប្បន្នទំហំ៤គុណនឹង៦ចំនួន ២(ពីរ)ច្បាប់

៤. លក្ខន្តិកៈចុះហត្ថលេខាដោយប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ២(ពីរ)ច្បាប់។

---

[15] A/HRC/RES/22/6 កថាខណ្ឌទី៤

**អនុសាសន៍**

*<u>ការចុះបញ្ជីជាកាតព្វកិច្ច៖</u> មាត្រា៦ អានរួមគ្នាជាមួយមាត្រា៩ ដែលតាមរយៈនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះបញ្ជី ដើម្បីអនុញ្ញាតឲ្យ "ធ្វើសកម្មភាពណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា" ដែលការនេះធ្វើឲ្យការចុះបញ្ជីគឺជាកាតព្វកិច្ច។ ចំណុចនេះ មានភាពប្រទាំងប្រទិសគ្នាជាមួយទស្សនៈរបស់តំណាងពិសេស អ.ស.ប ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស* (SRHRD) *ដែលតាមទស្សនៈរបស់គាត់៖ "ទោះជាលក្ខខណ្ឌតម្រូវពីការចុះបញ្ជីមិនចាំបាច់ក្តី លក្ខខណ្ឌតម្រូវនេះនៅរំលោភសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម*.... *ការចុះបញ្ជីមិនគួរជាកាតព្វកិច្ច ហើយ*... *អង្គការមិនមែនរដ្ឋាភិបាលដែលគួរត្រូវបានអនុញ្ញាតឲ្យបង្កើត និងអនុវត្តសកម្មភាពសមូហភាព ដោយមិនចាំបាច់ត្រូវចុះបញ្ជីឡើយ ប្រសិនជាអង្គការសមាគមនោះមិនមានបំណងធ្វើដូច្នេះ។ ម្យ៉ាងវិញទៀត អង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិចុះបញ្ជីជានីតិបុគ្គល និងមានសិទ្ធិទទួលអត្ថប្រយោជន៍ដែលខ្លួនអាចមានសិទ្ធិទទួលបាន"*[16] *ទស្សនៈនេះ ត្រូវបានថ្លែងបន្ទរ ឬគាំទ្រដោយអ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម* (SRFAA) *ដែលមានប្រសាសន៍ថា សមាគមគួរត្រូវបានផ្តល់ឲ្យដោយស្វ័យប្រវត្តិនូវបុគ្គលភាពគតិយុត្ត បន្ទាប់ពីបានជូនដំណឹងទៅអាជ្ញាធរ ដោយសមាជិកស្ថាបនិកពីការបង្កើតអង្គការនោះ។*[17] (*សូមអានសេចក្តីផ្តល់មតិរបស់ការិយាល័យ* OHCHR *លើមាត្រា៩ "លើកកម្ពស់របបជូនដំណឹង មិនមែនការចុះបញ្ជី។"*)

*ការិយាល័យ*OHCHR *កត់សម្គាល់ពីមតិយោបល់ដែលបានលើកឡើងនិងដែលបានគាំទ្រជាទូទៅនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកដំបូងលើសេចក្តីព្រាងច្បាប់នេះថា បញ្ញត្តិនេះ គួរតែធ្វើវិសោធនកម្មតាមរបៀបមួយដែលថាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនចុះបញ្ជីគួរត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិការនៅកម្ពុជា ប៉ុន្តែមិនទទួលបានឋានៈផ្លូវច្បាប់ ឬអត្ថប្រយោជន៍ដែលភ្ជាប់នឹងឋានៈនេះឡើយ។*

---

[16] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អប.ស. លេខ១៥ កថាខណ្ឌទី១

[17] A/៥៩កថាខណ្ឌទី 64/226

*<u>ភាពប្រទាំងប្រទិសគ្នាជាក្រមរដ្ឋប្បវេណី៖</u> មាត្រា១៨ និងមាត្រា១៩ នៃច្បាប់ឆ្នាំ២០១១ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី[18] អំពីនីតិបុគ្គល (រាប់ទាំងនីតិបុគ្គលមិនរកកម្រៃ) ចំពោះការចុះបញ្ជី ត្រូវបានកំណត់ដោយក្រសួងយុត្តិធម៌ រីឯមាត្រា៦ នៃសេចក្តីព្រាងច្បាប់នេះចែងថា ក្រសួងមហាផ្ទៃ "ទទួលខុសត្រូវលើការចុះបញ្ជីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក"។ លក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រា៥០ នៃក្រមរដ្ឋប្បវេណី មានលក្ខណៈខុសគ្នាផងដែរពីលក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រានេះ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ (សូមអានសេចក្តីផ្តល់មតិរបស់ការិយាល័យ* OHCHR *លើមាត្រា២ និងមាត្រា៣៩)*។

**មាត្រា៨៖**

ក្រសួងមហាផ្ទៃត្រូវពិនិត្យសំណុំលិខិតស្នើសុំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ហើយត្រូវសម្រេចព្រមទទួល ឬមិនព្រមទទួលចុះបញ្ជីរយៈពេលយ៉ាងយូរ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី ក្រសួងមហាផ្ទៃត្រូវជូន ដំណឹងជាលាលក្ខណ៍អក្សរទៅអ្នកស្នើសុំឲ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ ក្រសួងមហាផ្ទៃ ត្រូវសម្រេចអំពីការចុះបញ្ជី ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតកែតម្រូវ។

ក្នុងករណីក្រសួងមហាផ្ទៃខកខានមិនបានសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ខាងលើ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវចាត់ទុកថា បានទទួលការចុះបញ្ជីស្របតាមច្បាប់នេះ។ ក្នុងករណីនេះ ក្រសួងមហាផ្ទៃត្រូវធ្វើនិយតកម្មឯកសារចុះបញ្ជីផ្តល់ជូនទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ។

ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានរកឃើញថា មានគោលបំណង និងទិសដៅដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលក្រសួងមហាផ្ទៃសម្រេចបដិសេធចំពោះការស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងទៅតុលាការ។

---

[18] A/HRC/៦៨កថាខណ្ឌទី 20/27

**អនុសាសន៍**

*<u>ស្ថាប័នចុះបញ្ជី៖</u> តំណាងពិសេស អ.ស.ប ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស (SRHRD) បានណែនាំថា ស្ថាប័នចុះបញ្ជីគួរតែជាស្ថាប័នឯករាជ្យពីរដ្ឋាភិបាល និងបញ្ចូលតំណាងពីសង្គមស៊ីវិល។ ជាពិសេស សមាជិកនៃស្ថាប័នទាំងនេះ មិនគួរត្រូវបានតែងតាំងដោយផ្ទាល់ពីរដ្ឋាភិបាល ឬតាមឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ (A/៥៩/៤០១ កថាខណ្ឌទី៨២(ជ))[19]។ ក្រសួងមហាផ្ទៃ ច្បាស់ណាស់ គឺមិនមែនជាស្ថាប័នចុះបញ្ជីមួយឯករាជ្យឡើយ ដោយសារថា ស្ថាប័ននេះជាផ្លូវការ គឺស្ថិតក្រោមអង្គនីតិប្រតិបត្តិ។ ការប្រគល់ការកិច្ចចុះបញ្ជីទៅឲ្យក្រសួងនេះ គឺជាការបើកលទ្ធភាពឲ្យអង្គនីតិប្រតិបត្តិចូលជ្រៀតជ្រែកក្នុងប្រតិបត្តិការរបស់សង្គមស៊ីវិល ដល់សមត្ថភាពរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌ និងគណនេយ្យភាពពីរដ្ឋាភិបាល ជាការរួមចំណែកដ៏សំខាន់ដល់ការការពារសិទ្ធិមនុស្សនៅកម្ពុជា។*

*អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម (SRFAA) បានកត់សម្គាល់ដោយការពេញចិត្តថា ប្រទេសខ្លះ ជានាការត្រួតពិនិត្យជាទៀងទាត់ នូវការងាររបស់អង្គភាពរដ្ឋបាលអង្គការសមាគម លើការងារចុះបញ្ជី និងការពិនិត្យនីត្យានុកូលភាពអំពីរបៀបអនុវត្តនីតិវិធីចុះបញ្ជី។ ការនេះអនុញ្ញាតឲ្យមន្ត្រីទទួលខុសត្រូវខាងនីតិវិធី ទទួលបានជំនួយឧបត្ថម្ភផ្នែកជំនាញ និងការបកស្រាយច្បាប់។ អាស្រ័យហេតុនេះ អ្នករាយការណ៍ពិសេសរូបនេះ បានផ្តល់អនុសាសន៍ដល់រដ្ឋទាំងឡាយឲ្យ "ជានាផ្តល់ដល់មន្ត្រីរដ្ឋបាល និងមន្ត្រីអនុវត្តច្បាប់ នូវការបណ្តុះបណ្តាលគ្រប់គ្រាន់អំពីវិស័យដែលទាក់ទងនឹងការគោរពសិទ្ធិសេរីភាព ... ក្នុងការបង្កើតសមាគម។"[20]*

---

[19] ច្បាប់ឆ្នាំ២០១១ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ ជំពូកទី៣- ការចុះបញ្ជីនីតិបុគ្គល៖ មាត្រា១៨ : សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល៖ កិច្ចការ (១) រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការ (២) ដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល។ បញ្ជីនីតិបុគ្គល ត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌។ មាត្រា១៩៖ បែបបទ និងទម្រង់នៃការចុះបញ្ជីនីតិបុគ្គលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

[20] A/ 59/401កថាខណ្ឌទី៨២ (ជ)

អំណាចធ្វើសេចក្តីសម្រេចៈ ការិយាល័យ OHCHR ស្វាគមន៍ការកំណត់ពេលជាក់លាក់សម្រាប់ក្រសួងមហាផ្ទៃ ឆ្លើយតបទៅនឹងរាល់ពាក្យសុំចុះបញ្ជីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ការខកខាន ឬការមិនបានឆ្លើយតបនឹងត្រូវចាត់ទុកថាបានចុះបញ្ជី។ ទោះជាដូច្នេះក្តី ការទុករយៈពេល៤៥ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីសម្រេចពីនីត្យានុកូលភាពនៃលក្ខន្តិកៈសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល គឺជារយៈពេលមួយវែងនៅក្នុងអំឡុងពេលដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានបដិសេធសមត្ថភាពអនុវត្តសកម្មភាព និងអត្ថប្រយោជន៍ពីច្បាប់។ ទោះបីជាមានបញ្ញត្តិចែងថា ការខកខាន ឬការមិនបានឆ្លើយតបទៅនឹងពាក្យសុំចុះបញ្ជី នឹងត្រូវចាត់ទុកថាបានចុះបញ្ជីក្តី ក៏ក្រសួងមហាផ្ទៃនៅតែត្រូវរៀបចំសំណុំឯកសារផ្តល់នីត្យានុកូលភាពដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាដដែល។ ប្រការនេះអាចនឹងនាំឲ្យមានការអូសបន្លាយពេលវេលា ដែលនៅក្នុងអំឡុងពេលដែលគេនៅមិនទាន់ដឹងច្បាស់ ថាតើសាមីអង្គការនឹងត្រូវបាន ឬមិនត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិការឬយ៉ាងណា។ ប្រសិនជាអត់នោះ អញ្ចឹងការខ្វះសេចក្តីសម្រេចនេះ វាមិនផ្ទុយទៅនឹងគោលដៅដែលចង់បាន តាមការអនុវត្តជាក់ស្តែង វាគឺជាការបដិសេធការចុះបញ្ជី។ តំណាងពិសេស អ.ស.ប ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស (SRHRD) បានផ្តល់អនុសាសន៍ថា ប្រសិនជាមានប្រព័ន្ធចុះបញ្ជី "គេគួរតែធ្វើយ៉ាងណាឲ្យការចុះបញ្ជីប្រព្រឹត្តបានឆាប់រហ័ស។ ច្បាប់ត្រូវតែកំណត់រយៈពេលខ្លីជាអតិបរមាសម្រាប់ឲ្យអាជ្ញាធររដ្ឋធ្វើការឆ្លើយតបទៅនឹងពាក្យសុំចុះបញ្ជី ការខកខាន ឬការមិនផ្តល់ការឆ្លើយតប គួរតែបានចាត់ទុកថាអង្គការមិនមែនរដ្ឋាភិបាលនោះ បាននិងកំពុងប្រតិបត្តិការស្របច្បាប់។"[21]

**ការិយាល័យOHCHR ស្នើថារយៈពេលកំណត់នៃសេចក្តីសម្រេចអំពីការចុះបញ្ជីគួរបង្រួមឲ្យខ្លី ហើយប្រយោគដូចខាងក្រោមនេះ គួរតែបន្ថែមនៅខាងចុងកថាខណ្ឌទី៣ នៃមាត្រា៨៖ "នៅពេលរង់ចាំការរៀបចំឯកសារទាំងនេះដោយក្រសួងមហាផ្ទៃ (ឬស្ថាប័នចុះបញ្ជីមួយដែលឯករាជ្យ) សាមីសមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក អាចអនុវត្តសកម្មភាពទៅតាមលក្ខន្តិកៈរបស់ខ្លួន"។**

[21] A/ 59/401កថាខណ្ឌទី៨២ (គ)

*<u>ការបង្ហាញហេតុផលពីការបដិសេធនៃការចុះបញ្ជី៖</u> មាត្រា៨ អនុញ្ញាតឲ្យធ្វើការសម្រេចដោយគ្មានតម្លាភាព ដែលក្នុងនោះ មាត្រានេះ មិនតម្រូវឲ្យក្រសួងមហាផ្ទៃ ធ្វើលិខិតឆ្លើយតបជាលាយលក្ខណ៍អក្សរ បញ្ជាក់ប្រាប់ហេតុផលច្បាស់លាស់អំពីមូលហេតុដែលនាំឲ្យមានការបដិសេធនៃការស្នើសុំចុះបញ្ជីរបស់អ្នកដាក់ពាក្យ។ អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម (SRFAA) បានស្នើថា "ស្ថាប័នចុះបញ្ជី គួរតែផ្តល់សេចក្តីពន្យល់លម្អិតជាលាយលក្ខណ៍អក្សរទាន់ពេលវេលា ករណីបដិសេធការចុះបញ្ជីសមាគមណាមួយ"។*[22] **ការិយាល័យ OHCHR ស្នើថា ស្ថាប័នចុះបញ្ជី មានកាតព្វកិច្ចត្រូវធ្វើលិខិតឆ្លើយតបជាលាយលក្ខណ៍អក្សរបញ្ជាក់ប្រាប់ហេតុផលច្បាស់លាស់ចំពោះរាល់ការសម្រេចបដិសេធពាក្យសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណាមួយ។**

*<u>ការដាក់បណ្តឹង៖</u> ការិយាល័យ OHCHR ស្វាគមន៍ការអនុញ្ញាតដាក់លាក់សម្រាប់ការប្តឹងទៅតុលាការ ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួង។ ដោយសារតែការអូសបន្លាយពេលវែង សម្រាប់ករណីដែលត្រូវសម្រេចដោយតុលាការ និងក្នុងការរក្សាសំអាងថា ការចុះបញ្ជីមិនគួរជាកាតព្វកិច្ច (សូមអានសេចក្តីផ្តល់មតិលើមាត្រា៣)។* **ការិយាល័យ OHCHR ស្នើសុំបន្ថែមសេចក្តីនៅខាងចុងកថាខណ្ឌចុងក្រោយថា៖ "ក្នុងករណីដែលជាអ្នកដាក់ពាក្យសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដាក់បណ្តឹងទៅតុលាការ សាមីសមាគម ឬអង្គការនោះ ត្រូវបានចាត់ទុកថាបានចុះបញ្ជីហើយ ហើយរង់ចាំការសម្រេចរបស់តុលាការ។"**

*<u>មូលហេតុសម្រាប់ការបដិសេធ៖</u> ការិយាល័យ OHCHR កត់សម្គាល់ថា មូលហេតុដែលអាចប្រើជាយុត្តិកម្ម សម្រាប់បដិសេធការចុះបញ្ជីតាមមាត្រានេះ គឺមានលក្ខណៈទូលាយជាងមូលហេតុ ដែលអាចអនុញ្ញាតឲ្យបានសម្រាប់ការរឹតត្បិត លើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមដែលមានចែងក្នុងកថាខណ្ឌទី២ មាត្រា២២ នៃកតិកាសញ្ញាICCPR ដែលបើតាមកតិកាសញ្ញានេះ ការរឹតត្បិតអនុញ្ញាតតែក្នុងករណី "ដែលចាំបាច់នៅក្នុងសង្គម*

[22] A/HRC/៩៥កថាខណ្ឌទី 20/27

*ប្រជាធិបតេយ្យ ជាផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។" (សូមអានសេចក្តីផ្តល់មតិរបស់ការិយាល័យOHCHR លើមាត្រា៦)។*

**ការិយាល័យ OHCHR ស្នើឲ្យមានការរៀបចំតាក់តែងមាត្រា៨ ឡើងវិញ ដើម្បីឲ្យស្របតាមមាត្រា២២ កថាខណ្ឌទី២ នៃកតិកាសញ្ញា ICCPR។**

*"ស្ថិរភាព" "ឯកភាពជាតិ"៖ ប្រសិនជាមានការលើកឡើងណាមួយ ដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដើម្បីអនុវត្តវិធីសាស្ត្រល្អប្រសើរជាងនេះ ក្នុងការអនុវត្តសិទ្ធិមនុស្ស ដោយអំពាវនាវឲ្យកែប្រែ ឬផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន អាចត្រូវបានគេបកស្រាយថាជំទាស់នឹង "ស្ថិរភាព" ឬ "ឯកភាពជាតិ" ដូច្នេះការតស៊ូមតិដើម្បីភាពរីកចម្រើន អាចត្រូវរាំងស្ទះ ដូច្នេះហើយ វឌ្ឍនភាពរបស់កម្ពុជាឆ្ពោះទៅសម្រេចបានសិទ្ធិមនុស្ស អាចនឹងជួបឧបសគ្គមួយដ៏ធំ។ គោលគំនិតពិតប្រាកដនៃលទ្ធិប្រជាធិបតេយ្យផ្អែកលើមូលដ្ឋានសមាសភាគចម្រុះនៃសង្គម ឈានដល់ការដោះស្រាយបញ្ហាក្នុងសង្គមតាមរយៈការសន្ទនាឈរលើសេរីភាពក្នុងការបញ្ចេញមតិ ដែលត្រូវបានការពារយ៉ាងមុតមាំពីច្បាប់សិទ្ធិមនុស្ស។[23]*

**ការិយាល័យ OHCHR ស្នើឲ្យមានការរៀបចំតាក់តែងមាត្រា៨ ឡើងវិញ ដើម្បីឲ្យស្របតាមមាត្រា២២ កថាខណ្ឌទី២ នៃកតិកាសញ្ញា ICCPR។**

*"វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា"៖ ការរិតត្បិតលើសេរីភាពក្នុងការបង្កើតសមាគម ដោយសារការគំរាមកំហែងដល់ "ឯកភាពជាតិ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា" មិនស្ថិតក្នុងចំណោមហេតុផលដែលអនុញ្ញាតសម្រាប់ការរិតត្បិតដែលមានចែងក្នុងមាត្រា២២ កថាខណ្ឌទី២ នៃកតិកាសញ្ញា ICCPR ឡើយ។ ភាពមិនច្បាស់លាស់នៃគំនិត ឬទស្សនទាននីមួយៗអំពី "វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់" បង្កើតជាកង្វល់អំពីលទ្ធភាពអនុវត្តតាមអំពើចិត្ត ជាពិសេស ក្នុងសភាពដែលមានកង្វះនិយមន័យក្នុងសេចក្តីព្រាងនេះអំពីថាតើអ្វីខ្លះដែលចាត់ថាជាវប្បធម៌ជាតិ*

[23] មាត្រា១៩ នៃកតិកាសញ្ញា ICCPR

និងកង្វះការយកចិត្តទុកដាក់ពីតុល្យភាពដល់ការអភិរក្សវប្បធម៌ជនជាតិភាគតិច។ អ្នករាយការណ៍ពិសេស អ ប.ស.ស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម (SRFAA) បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃសេរីភាពក្នុងការបង្កើតសមាគម ដែលត្រូវតែទទួលបានការការពារផងដែរ សម្រាប់ក្រុមជនភាគតិច ដែលបើពុំនោះទេ ពួកគេអាចប្រឈមនឹងការលំបាកក្នុងការបង្កើតសមាគម ដែលមានគោលដៅការពារ និងអភិរក្សវប្បធម៌របស់ខ្លួន។[24]

កាតព្វកិច្ចការពារសិទ្ធិវប្បធម៌ មិនអាចចែកដាច់ចេញពីកាតព្វកិច្ចការពារភាពចំរុះគ្នានៃវប្បធម៌បានឡើយ ដោយផ្អែកលើ (ក)ការទទួលស្គាល់ភាពចំរុះគ្នានៃអត្តសញ្ញាណ និងការបញ្ចេញមតិយោបល់ខាងវប្បធម៌ (ខ)ការប្រព្រឹត្តដោយស្មើភាពគ្នា និងការគោរពចំពោះសេចក្តីថ្លៃថ្នូរដោយស្មើគ្នាចំពោះសហគមន៍ និងបុគ្គលគ្រប់រូប ដោយគ្មានការរើសអើង ដោយសារហេតុផលខាងអត្តសញ្ញាណវប្បធម៌របស់ពួកគេ និង(គ) ភាពបើកចំហដល់អ្នកដទៃទៀត ការពិភាក្សា និងការផ្លាស់ប្តូរវប្បធម៌គ្នាទៅវិញទៅមក។ យោងតាមអ្នកជំនាញការឯករាជ្យរបស់ អ.ស.ប ក្នុងវិស័យសិទ្ធិវប្បធម៌ វប្បធម៌គឺជាដំណើររស់រវើក និងមានថាមពលៈ "បញ្ហាប្រឈមមិនជាធ្ងន់ធ្ងរនោះទេ សម្រាប់រក្សាអភិរក្សតម្លៃ និងការប្រតិបត្តិវប្បធម៌...ប៉ុន្តែបញ្ហាប្រឈមដ៏ធំនោះគឺរក្សាអភិរក្សលក្ខខណ្ឌនានាដែលអាចផ្តល់លទ្ធភាពអាចឲ្យតម្លៃ និងការប្រតិបត្តិទាំងនេះអាចធ្វើទៅបាន ដើម្បីបង្កើតនិងអភិវឌ្ឍ។"[25]

ការតាក់តែងមាត្រា៨ បច្ចុប្បន្ននេះ លើសពីកម្រិតនៃការរិតត្បិតដែលអាចអនុញ្ញាតបានទៅលើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ហើយម្យ៉ាងវិញទៀត មាត្រានេះបញ្ចូលវិធីសាស្ត្រដែលអ្នកជំនាញការរបស់យន្តការសិទ្ធិមនុស្ស អ.ស.ប មិនជម្រុញលើកទឹកចិត្តលើប្រធានបទនេះ ដោយព្យាយាមការពារ "វប្បធម៌ជាតិ" ដូចនេះ ដោយមិនផ្តល់និយមន័យថាវាជាអ្វី ជាជាងការគ្រាន់តែទទួលស្គាល់សមាសភាគផ្សេងៗគ្នានៃវប្បធម៌ និងការរក្សាលក្ខខណ្ឌដែលអាចឲ្យវប្បធម៌ចេញជារូបរាងឡើង។

---

[24] A/HRC/៥កថាខណ្ឌទី 26/29៣

[25] របាយការណ៍របស់អ្នកជំនាញការឯករាជ្យក្នុងវិស័យសិទ្ធិវប្បធម៌ A/HRC/៣០កថាខណ្ឌទី 14/36

*ការិយាល័យ OHCHR ស្នើឲ្យតាក់តែងមាត្រា៨ នេះឡើងវិញឲ្យស្របតាមមាត្រា២២ កថាខណ្ឌទី២ នៃកតិកាសញ្ញា ICCPR។*

**មាត្រា៩៖**

សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នឹងក្លាយជានីតិបុគ្គល ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី។ ក្រសួងមហាផ្ទៃត្រូវចម្លងឯកសារចុះបញ្ជីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនេះ ទៅក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

**អនុសាសន៍**

*<u>លើកកម្ពស់របបជូនដំណឹង មិនមែនរបបចុះបញ្ជី៖</u> តំណាងពិសេស អ.ស.ប ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស(SRHRD) ទទួលស្គាល់ថា រដ្ឋអាចគ្រប់គ្រងលើសេរីភាពរបស់សមាគម ប៉ុន្តែជម្រុញលើកទឹកចិត្តឲ្យរដ្ឋទាំងនោះអនុម័តរបបឆាប់រហ័សនៃ "ការប្រកាស" ឬ "ការជូនដំណឹង" ដោយចាត់ទុកអង្គការសមាគមជានីតិបុគ្គលភ្លាមក្រោយពីបានជូនដំណឹងអំពីការបង្កើតអង្គការសមាគមនោះទៅរដ្ឋបាលពាក់ព័ន្ធ ដោយផ្តល់ព័ត៌មានជាមូលដ្ឋាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់ស្ថាបនិក និងឈ្មោះ អាសយដ្ឋាន លក្ខន្តិកៈ និងគោលដៅរបស់អង្គការសមាគម (សូមអានសេចក្តីផ្តល់មតិរបស់ការិយាល័យ OHCHR លើមាត្រា៦)។[26] បើតាមអ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម (SRFAA) "នីតិវិធីជូនដំណឹង" ប្រសើរជាង "នីតិវិធីសុំការអនុញ្ញាតជាមុន" អនុវត្តបានប្រសើរជាងស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយការផ្តល់បុគ្គលភាពគតិយុត្តដល់សមាគម (និងអង្គការ) ភ្លាម បន្ទាប់ពីស្ថាបនិកបានជូនដំណឹងទៅអាជ្ញាធរអំពីការបង្កើតអង្គការសមាគមនោះ។ នៅប្រទេសភាគច្រើន ការជូនដំណឹងនេះ ធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ច្បាស់ពីចំណុចមួយចំនួនដែលបានកំណត់ក្នុងច្បាប់។*

[26] A/ 59/401កថាខណ្ឌទី៨២ (ខ)

ការជូនដំណឹងមិនមែនជាបុរេលក្ខខណ្ឌសម្រាប់ការបង្កើតសមាគមមួយឡើយ ផ្ទុយទៅវិញ វាគ្រាន់តែជាការដាក់ពាក្យសុំរាប់ជាការកត់ត្រារដ្ឋបាលស្តីពីការបង្កើតសមាគមខាងលើនេះប៉ុណ្ណោះ។[27]

<u>ការសន្មត់ជាមុនពីនីត្យានុកូលភាព៖</u> ទន្ទឹមនឹងយន្តការសិទ្ធិមនុស្សអន្តរជាតិ បានគូសបញ្ជាក់ថា អង្គការសង្គមស៊ីវិល ត្រូវបានសន្មត់ថាបាននិងកំពុងប្រតិបត្តិការស្របច្បាប់ រហូតដល់មានភស្តុតាងផ្ទុយ នៅក្នុងអំឡុងពេលដំណើរការចុះបញ្ជីទាំងមូល មាត្រា៩ នៃច្បាប់នេះ តម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចុះបញ្ជី ដើម្បីបានការអនុញ្ញាតឲ្យ "ធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា" គឺជាការធ្វើឲ្យការចុះបញ្ជី គឺជាកាតព្វកិច្ចប្រសិទ្ធភាព។ ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា មិនតម្រូវឲ្យអង្គការសមាគមណាមួយចុះបញ្ជីឡើយ។ មាត្រា៤៩ នៃក្រមរដ្ឋប្បវេណី ចែងថា៖ "នីតិបុគ្គលត្រូវបានបង្កើតឡើង ដោយការចុះបញ្ជីនៅកន្លែងដែលមានទីតាំងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ។" បទប្បញ្ញត្តិផ្សេងៗនៃក្រមរដ្ឋប្បវេណីជារួមចែងពីកិច្ចការពារតាមផ្លូវច្បាប់ដល់សមាជិកអង្គការសមាគម ប្រឆាំងទៅនឹងភាគីទីបី ឬតតីយជន លើបញ្ហាការទទួលខុសត្រូវជាប្រយោជន៍ចម្បងនៃការចុះបញ្ជី។ វាគឺសម្រាប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ ជាអ្នកសម្រេចចិត្តថាតើត្រូវទទួលយកការទទួលខុសត្រូវ និងហានិភ័យពាក់ព័ន្ធនេះ ឬយ៉ាងណា។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជី មិនគួរត្រូវបានដាក់ទោសទណ្ឌឡើយ ប្រសិនបើសកម្មភាពរបស់អង្គការសមាគមនោះ មិនបំពានលើច្បាប់ផ្សេងទៀត។

អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម(SRFAA) បានសង្កត់ធ្ងន់ថា សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ត្រូវយកមកអនុវត្តដោយស្មើភាពគ្នាចំពោះសមាគមក្រៅផ្លូវការដែលមិនបានចុះបញ្ជី[28] និងបានផ្តល់អនុសាសន៍ថា "សមាគមណាក៏ដោយរាប់ទាំងសមាគមដែល

---

[27] A/HRC/ 20/27កថាខណ្ឌទី៥៨

[28] A/HRC/ ៩៦និងកថាខណ្ឌទី ៥៦កថាខណ្ឌទី 20/27A/HRC/៨២កថាខណ្ឌទី 23/39 A/HRC/និង ៥៥កថាខណ្ឌទី 26/29A/HRC/កថា 29/25 ៥៩ខណ្ឌទី

*មិនបានចុះបញ្ជីផងដែរ គួរតែត្រូវបានអនុញ្ញាតឲ្យដំណើរការបានដោយសេរី ហើយសមាជិករបស់សមាគមនោះ អាចប្រតិបត្តិការសកម្មភាពប្រកបដោយបរិយាកាសងាយស្រួល និងមានសុវត្ថិភាព។[29] លោកបានបន្តអំពាវនាវឲ្យ "រដ្ឋទាំងឡាយ.... ធានាថាសមាគមទាំងឡាយ - ទាំងសមាគមដែលបានចុះបញ្ជី ទាំងសមាគមដែលមិនបានចុះបញ្ជី - អាចស្វែងរក ទទួលយកនិងប្រើប្រាស់មូលនិធិ និងធនធានដទៃផ្សេងទៀតពីរូបវន្តបុគ្គល និងនីតិបុគ្គល មិនថា សមាគមនោះជាសមាគមក្នុងស្រុក ជាសមាគមបរទេស ឬជាសមាគមអន្តរជាតិ ដោយមិនចាំបាច់មានការអនុញ្ញាតជាមុន ឬឧបសគ្គហួសហេតុផ្សេងទៀតឡើយ ..."[30]*

*ការិយាល័យ OHCHR ស្នើសុំឲ្យធ្វើវិសោធនកម្មមាត្រា៩ ដើម្បីបង្កើតរបបជូនដំណឹងដូចខាងក្រោម៖ សមាគមក្នុងស្រុក (ឬអង្គការមិនមែនរដ្ឋាភិបាល) នឹងក្លាយទៅជានីតិបុគ្គលមួយ ចាប់ពីកាលបរិច្ឆេទដែលសមាគមជូនដំណឹងទៅក្រសួងមហាផ្ទៃដែលមានព័ត៌មានដូចខាងក្រោមនេះ៖ ឈ្មោះ និងអាសយដ្ឋានរបស់ស្ថាបនិក និងឈ្មោះ អាស័យដ្ឋាន លក្ខន្តិកៈ និងគោលបំណងរបស់អង្គការ។ ក្រសួងមហាផ្ទៃ ត្រូវបញ្ជូនសេចក្តីចម្លងចំនួនមួយច្បាប់ នៃឯកសាររបស់សមាគមក្នុងស្រុក ឬអង្គការមិនមែនរដ្ឋាភិបាល ទៅក្រសួងពាក់ព័ន្ធ តាមការចាំបាច់។"*

**មាត្រា១១៖**

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក សម្រាប់នីតិបុគ្គល និងសម្រាប់ជនបរទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុក សម្រាប់អនីតិជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

---

[29] A/HRC/20/27 កថាខណ្ឌទី៩៦

[30] A/HRC/ 23/39កថាខណ្ឌទី៨២ (ខ)

**អនុសាសន៍**

*<u>ការចុះបញ្ជី៖</u> ទន្ទឹមនឹងការរក្សាជំហរដែលថា របបនៃការជូនដំណឹងនេះ មានលក្ខណៈសមស្របទៅនឹងច្បាប់សិទ្ធិមនុស្សច្រើនជាងប្រព័ន្ធសុំច្បាប់អនុញ្ញាតជាមុននោះ ការិយាល័យ* OHCHR *យល់ថា ប្រកាសដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងចេញនោះ នឹងនិយាយតែពីលក្ខខណ្ឌសម្រាប់ការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ ប៉ុណ្ណោះ គឺមិនបន្ថែមលក្ខខណ្ឌ ឬដាក់ពិន័យថ្មីទៀតឡើយ។*

*<u>បែបបទសម្រាប់អនីតិជន៖</u> ចំណុចនេះ មិនសមស្របសម្រាប់ច្បាប់ស្តីពីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលហាមប្រាមអនីតិជនមិនឲ្យបង្កើត និងចុះបញ្ជីសមាគម ហើយបែរជាអនុញ្ញាតឲ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃចេញប្រកាសមួយគ្រប់គ្រងលើកិច្ចដំណើរការនេះ។ សូមអានសេចក្តីផ្តល់មតិរបស់ការិយាល័យ* OHCHR *និយាយពី "អាយុអប្បបរមារបស់សមាជិកស្ថាបនិក"។*

## ជំពូកទី៣
## ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស

**មាត្រា១២៖**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានបំណងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមទម្រង់ជាការចុះអនុស្សរណៈ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានបំណងអនុវត្តគម្រោងរយៈពេលខ្លី ត្រូវសុំការអនុញ្ញាតពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដោយផ្ទាល់ ឬតាមរយៈដៃគូក្នុង ស្រុក។

**អនុសាសន៍**

*<u>ស្ថាប័នចុះបញ្ជី៖</u> តំណាងពិសេស អ.ស.ប ស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស* (SRHRD) *បានណែនាំថាស្ថាប័នចុះបញ្ជីគួរតែជាស្ថាប័នឯករាជ្យពីរដ្ឋាភិបាល និងបញ្ចូលតំណាងពីសង្គមស៊ីវិល។ ជាពិសេស សមាជិកនៃស្ថាប័នទាំងនេះ មិនគួរត្រូវបានតែងតាំងដោយផ្ទាល់ពីរដ្ឋាភិបាល ឬតាមឆន្ទានុសិទ្ធរបស់ខ្លួនឡើយ។*[31] *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គឺជាផ្នែកមួយនៃអង្គនីតិប្រតិបត្តិ ច្បាស់ណាស់ គឺមិនមែនជាស្ថាប័នមួយឯករាជ្យឡើយ (សូមអានសេចក្តីផ្តល់មតិរបស់ការិយាល័យ* OHCHR *លើមាត្រា៨ "ស្ថាប័នចុះបញ្ជី" និងមាត្រា៣០)។*

*<u>"គម្រោងរយៈពេលខ្លី"៖</u>មាត្រា១២បង្កើតលក្ខខណ្ឌតម្រូវថ្មីមួយសម្រាប់គម្រោងរយៈពេលខ្លីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលត្រូវបានអនុម័តយល់ព្រមដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ចំណុចនេះ មានលក្ខណៈស្រពិចស្រពិលអំពីពាក្យថាគម្រោងរយៈពេលខ្លីឬថាតើផ្នែកមួយចំនួនណានៃសកម្មភាពរួម អាចស្ថិតក្រោមជំពូកនេះ។ ជាទូទៅ កិច្ចសហប្រតិបត្តិការអន្តរជាតិ គួរតែត្រូវបានជំរុញលើកទឹកចិត្តសម្រាប់គោលបំណងចែករំលែកជំនាញ ធនធាន និងបទពិសោធន៍គ្នា*

---

[31] A/59/401 កថាខណ្ឌទី៨២ (ជ)

*ទៅវិញទៅមក ជាជាងការដាក់ការរឹតត្បិត។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលកម្ពុជាគឺជាភាគីមួយ តម្រូវឲ្យរដ្ឋភាគីទាំងឡាយ "ចាត់វិធានការដោយខ្លួនឯងផ្ទាល់ និងតាមរយៈជំនួយនិងសហប្រតិបត្តិការអន្តរជាតិ ជាពិសេសខាងសេដ្ឋកិច្ច និងបច្ចេកទេស" សម្រាប់ការធ្វើឲ្យរីកចម្រើនជាលំដាប់នូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា២ កថាខណ្ឌទី១) និង "ដើម្បីទទួលស្គាល់អត្ថប្រយោជន៍ដែលបានមកពីការលើកទឹកចិត្ត និងការអភិវឌ្ឍន៍នៃសហប្រតិបត្តិការ និងការទាក់ទងជាអន្តរជាតិក្នុងវិស័យវិទ្យាសាស្ត្រ និងវប្បធម៌។" មាត្រា១៥ កថាខណ្ឌទី៤)។*

***ការិយាល័យ OHCHR សូមស្នើដកកថាខណ្ឌទី២ ចេញ។ ប្រសិនជារក្សាទុកកថាខណ្ឌនេះ ការិយាល័យ OHCHR សូមស្នើឲ្យធ្វើវិសោធនកម្មកថាខណ្ឌទី២ ដើម្បីបញ្ចូលនិយមន័យនៃពាក្យ "គម្រោងរយៈពេលខ្លី" និងស្នើឲ្យដាក់ជំនួសពាក្យសុំការអនុញ្ញាត ដោយពាក្យលក្ខខណ្ឌតម្រូវឲ្យជូនដំណឹងវិញ។***

*<u>លក្ខខណ្ឌតម្រូវឲ្យចុះអនុស្សរណៈយោគយល់គ្នា(MOU)៖</u> លក្ខខណ្ឌតម្រូវក្នុងមាត្រានេះអនុវត្តសម្រាប់អនុស្សរណៈយោគយល់គ្នាជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បង្កើតជាករណីមួយដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបដិសេធការអនុញ្ញាតដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលធ្វើសកម្មភាពស្របច្បាប់។ យោងតាមមាត្រា១៤ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មិនត្រូវបានតម្រូវឲ្យពន្យល់ពីការទទួលយក ឬច្រានចោលពាក្យសុំឡើយ (សូមមើលសេចក្តីផ្តល់មតិរបស់ការិយាល័យ OHCHR លើមាត្រា១៤)។ ដោយសារសកម្មភាពដែលមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ត្រូវបានហាមប្រាមរួចហើយ និងផ្តន្ទាទោសក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជា បញ្ញត្តិនេះមិនផ្តល់កិច្ចការពារបន្ថែមប្រឆាំងនឹងសកម្មភាពខុសច្បាប់ឡើយ។*

**មាត្រា១៣៖**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងអនុវត្តគម្រោងនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម៖

១. លិខិតរបស់ប្រធានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានទីស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេស ស្នើតែងតាំងតំណាងរបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលស្នើតែងតាំងចំនួន ១(មួយ)ច្បាប់ និងស្នើបើកទីស្នាក់ការតំណាង១ច្បាប់

២. លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការតំណាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីមេឃុំ/ចៅសង្កាត់ចំនួន ១(មួយ)ច្បាប់

៣. លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចប្រទេសដើម អនុញ្ញាតឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដំណើរការចំនួន ១(មួយ)ច្បាប់

៤. លិខិតគាំទ្រគម្រោងនានារបស់សមាគមន ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ចេញដោយអាជ្ញាធរសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១(មួយ)ច្បាប់

៥. លិខិតបញ្ជាក់ពីចំនួនថវិកា សម្រាប់អនុវត្តគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស រយៈពេលយ៉ាងតិច៦(ប្រាំមួយ)ខែ បញ្ជាក់ដោយទីស្នាក់ការអចិន្ត្រៃយ៍នៅបរទេសចំនួន ១(មួយ)ច្បាប់

៦. លិខិតសន្យាផ្តល់នូវរាល់គណនីនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួន ១(មួយ)ច្បាប់។

**អនុសាសន៍៖**

*បញ្ជីសំណុំលិខិតដែលតម្រូវ ដើម្បីដាក់ពាក្យសុំអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហាក់ដូចជាមានលក្ខណៈគួរឲ្យបារម្ភ ដោយសារតែមានការពិចារណាទាំងទៅលើទិដ្ឋភាពច្បាប់ ទាំងទៅលើការអនុវត្តជាក់ស្តែង។ មាត្រា១៣ កថាខណ្ឌទី១ តម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលបរទេស ផ្តល់នូវ "ជីវប្រវត្តិសង្ខេប" របស់បុគ្គល ដែលពួកគេមានបំណងចង់តែងតាំងជាតំណាង ដែលត្រូវដាក់រួមគ្នាជាមួយនឹង "សំណើបើកការិយាល័យតំណាងនេះ"។ ក្នុងការអនុវត្តន៍ជាក់ស្តែង វាមិនទំនងសោះដែលថា ការជ្រើសរើសបុគ្គលិកនៅបរទេសចាប់ផ្តើមមុនអង្គការក្រៅរដ្ឋាភិបាលបរទេស*

ត្រូវបានជានាពីលទ្ធភាពបើកការិយាល័យថ្មីនេះនៅក្រៅប្រទេស។ ការផ្ដល់ជីវប្រវត្តិសម្រាប់មុខតំណែងជាតំណាងនេះ នឹងអាចធ្វើទៅបាន ប៉ុន្តែមិនចាំបាច់ត្រូវផ្ដល់ជីវប្រវត្តិរបស់បុគ្គលដែលបានស្នើតែងតាំងឡើយ។ តម្រូវការលិខិតសន្យាផ្ដល់នូវឈ្មោះ និងព័ត៌មានទាក់ទងរបស់តំណាង នៅពេលដែលត្រូវបានតែងតាំងរួចរាល់ហើយ គួរតែមានប្រសិទ្ធភាពជាង ដូចមានចែងនៅក្នុងមាត្រា១៣ កថាខណ្ឌទី៦។

មាត្រា១៣ កថាខណ្ឌទី២ បង្ហាញពីភាពចម្រូងចម្រាស់ស្រដៀងគ្នាមួយ នៅក្នុងការកំណត់ពេលវេលា៖ វាតម្រូវឲ្យមាន "លិខិតបញ្ជាក់អាសយដ្ឋាននៃការិយាល័យតំណាងពីមេឃុំ ឬចៅសង្កាត់។" ប្រសិនបើច្បាប់នេះត្រូវបានប្រកាសឲ្យប្រើក្នុងទម្រង់បច្ចុប្បន្ននេះ វាអាចនឹងមានការលំបាក ប្រសិនបើមិនអាចធ្វើទៅបានដោយផ្អែកតាមទិដ្ឋភាពច្បាប់ដើម្បីចុះកិច្ចសន្យាជួលបង្កើតការិយាល័យតំណាងមួយ មុនពេលត្រូវបានទទួលស្គាល់ជានីតិបុគ្គល ដោយចុះអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ តម្រូវការលិខិតសន្យាផ្ដល់នូវអាសយដ្ឋានក្នុងស្រុកនៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលបរទេសបានចុះហត្ថលេខាលើអនុស្សរណៈហាក់ដូចជាមានប្រសិទ្ធភាពជាង។

*ការិយាល័យ OHCHR សូមផ្ដល់អនុសាសន៍ឲ្យពិនិត្យឡើងវិញនូវលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងមាត្រា១៣ ដើម្បីធានាថា បទប្បញ្ញត្តិទាំងនោះមិនមានលក្ខខណ្ឌតម្រូវណាដែលមិនអាចអនុវត្តបាននោះទេ ដែលអាចនឹងរិតត្បិតមិនចាំបាច់ដល់សមត្ថភាពរបស់សមាគមបរទេសក្នុងការធ្វើប្រតិបត្តិការនៅកម្ពុជា ដោយរំលោភលើមាត្រា២២ កថាខណ្ឌទី២ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។*

**មាត្រា១៤៖**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យខ្លឹមសារនៃសំណុំលិខិត ហើយត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមចុះអនុស្សរណៈជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសយ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។

**អនុសាសន៍៖**

*<u>អវត្តមាននៃកាតព្វកិច្ចក្នុងការពន្យល់ពីការបដិសេធពាក្យសុំ៖</u> ប្រសិនបើអនុស្សរណៈត្រូវបានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បដិសេធ ការដែលពុំមានលក្ខខណ្ឌតម្រូវដាក់លាក់មួយសម្រាប់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ធ្វើការពន្យល់ពីសេចក្តីសម្រេចរបស់ខ្លួននោះ ធ្វើឲ្យអ្នកដាក់ពាក្យស្នើសុំ ស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់ និងងាយរងគ្រោះ។ យោងតាមអ្នករាយការណ៍ពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្ស (SRHRD) និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម (SRFAA) សេចក្តីសម្រេចនានាដើម្បីបដិសេធការចុះបញ្ជីត្រូវតែផ្តល់ការពន្យល់ឲ្យបានពេញលេញ និងមិនអាចធ្វើឲ្យទៅជារឿងនយោបាយឡើយ ហើយការខកខានមិនបានផ្តល់ហេតុផលលម្អិតចំពោះសេចក្តីសម្រេចទាំងនេះ គួរតែជាលទ្ធផលដែលធ្វើឲ្យអង្គការមិនមែនរដ្ឋាភិបាលត្រូវបានចាត់ទុកថាអាចប្រតិបត្តិការដោយស្របច្បាប់បាន។[32] វាគឺជាគោលការណ៍ស្នូលនៃច្បាប់រដ្ឋបាលដែលថា សេចក្តីសម្រេចនានារបស់រដ្ឋាភិបាល គួរមានផ្តល់ហេតុផល។ ទោះបីជានៅតែរក្សាជំហរថា របបជូនដំណឹង ប្រសើរជាងប្រព័ន្ធដាក់ពាក្យសុំដែលនឹងច្រានចោលសេចក្តីត្រូវការចំពោះអនុសាសន៍ខាងក្រោម ប្រសិនបើនៅតែរក្សាទុកប្រព័ន្ធដាក់ពាក្យសុំនេះនោះ* ***ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា អត្ថបទដូចខាងក្រោមគួរបន្ថែមនៅក្នុងមាត្រា១៤៖ "រាល់សេចក្តីសម្រេចបដិសេធពាក្យស្នើសុំមួយ ត្រូវរាប់បញ្ចូលការពន្យល់លម្អិតអំពីហេតុផលនៃសេចក្តីសម្រេច។ ក្នុងករណីមិនមានចេញសេចក្តីសម្រេចលើពាក្យស្នើសុំក្នុងអំឡុងកាលបរិច្ឆេទ ដែលមានកំណត់ក្នុងមាត្រានេះ អនុស្សរណៈត្រូវចាត់ទុកថាមានសុពលភាព។"***

*<u>ពេលវេលាកំណត់សម្រាប់ការធ្វើសេចក្តីសម្រេច៖</u> បើកាលបរិច្ឆេទបានកន្លងផុត ដោយមិនមានសេចក្តីសម្រេចណាមួយនោះ ការខកខានរបស់រដ្ឋាភិបាលក្នុងការបំពេញតាមកាលបរិច្ឆេទនេះ មិនគួរជាការប៉ះពាល់ដល់អ្នកដាក់ពាក្យសុំនោះទេ។ រំលឹកឡើងវិញពី*

[32] A/HRC/20/27 កថាខណ្ឌទី៩៥ និង A/59/401 កថាខណ្ឌទី៨២(ឃ)

*អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមថា ដំណើរការចុះបញ្ជីណាមួយ ដែលត្រូវបាន បង្កើតឡើង ត្រូវតែធ្វើឲ្យបានឆាប់តាមតែអាចធ្វើបាន* ***ហើយការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ ឲ្យបន្ថយពេលកំណត់៤៥ថ្ងៃ ក្នុងការធ្វើសេចក្តីសម្រេចមួយនោះ។***

*<u>សិទ្ធិដាក់ពាក្យបណ្តឹង៖</u> យោងតាម SRFAA និង SRHRD សេចក្តីសម្រេចទាក់ទងនឹងការបដិសេធនៃការចុះបញ្ជី ឬការដាក់ការរឹតត្បិតណាមួយ គួរតែធ្វើដោយមិនលំអៀង ឯករាជ្យនិងមានការត្រួតពិនិត្យភ្លាមៗតាមផ្លូវតុលាការ*[33] *ដែលត្រូវបានមើលឃើញជាមុនក្នុងករណីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្នុងមាត្រា៨ និង៣១ នៃសេចក្តីព្រាងច្បាប់នេះ។*

***ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ក៏អាចប្តឹងទៅតុលាការនូវសេចក្តីសម្រេចនានាដែលបដិសេធខ្លួនមិនឲ្យចុះបញ្ជីបានដែរ។***

*<u>ទំនាស់នឹងក្រមរដ្ឋប្បវេណី៖</u> ការិយាល័យ OHCHR បន្តកត់សម្គាល់ឃើញថា មាត្រា១៤ ចែងថា ក្រសួងការបរទេស នឹងអនុម័តលើពាក្យស្នើសុំចំពោះអង្គភាពបរទេស ចំណែកឯមាត្រា១៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីចែងថា ការចុះបញ្ជី ត្រូវស្ថិតនៅក្រោមបញ្ជាពីក្រសួងយុត្តិធម៌។ (សូមមើលសេចក្តីផ្តល់មតិរបស់ការិយាល័យរបស់ OHCHR លើមាត្រា៣៩)។*

**មាត្រា១៦៖**

អនុស្សរណៈមានសុពលភាពរយៈពេលយ៉ាងយូរ ៣(បី)ឆ្នាំ ដោយផ្អែកតាមគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស។ សុពលភាពអនុស្សរណៈនឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិក្រោយថ្ងៃផុតកំណត់។

ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស មានបំណងបន្តសុពលភាពអនុស្សរណៈ ត្រូវដាក់ពាក្យសុំបន្តសុពលភាពអនុស្សរណៈឲ្យបាន៩០ (កៅសិប) ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សរណៈ។

---

[33] A/HRC/20/27 កថាខណ្ឌទី៩៥ A/HRC/23/39 កថាខណ្ឌទី៨១(គ) និង A/59/401 កថាខណ្ឌទី៨២(ញ)

**អនុសាសន៍៖**

*ពេលវេលាសំរាប់ការដាក់សំណើរដើម្បីបន្តសុពលភាពនៃអនុស្សរណៈដែលបានកំណត់ ៩០ថ្ងៃ គឺជារយៈពេលទ្វេដងនៃរយៈពេល៤៥ថ្ងៃ ដែលតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំថ្មី ស្របតាមមាត្រា១៤។ ហេតុអ្វីបានជាការពិចារណាទៅលើអង្គការដែលបានស្គាល់រួចហើយ ត្រូវចំណាយពេលវេលាទ្វេដង នៃពេលវេលាចាំបាច់ក្នុងការពិចារណាអង្គការថ្មីមួយដែលមិនមានអ្វីច្បាស់លាស់នោះ។ ទស្សនៈនៃពហុយន្តការសិទ្ធិមនុស្ស គឺថា បទប្បញ្ញត្តិនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល គួរតែជារបបជូនដំណឹងដោយផ្អែកលើសច្ចាធារណ៍នៃនីត្យានុកូលភាព (សូមមើលសេចក្តីផ្តល់មតិរបស់ការិយាល័យOHCHR លើមាត្រា៨ និង៩)។ ដោយតម្រូវឲ្យមានការចុះឈ្មោះជាថ្មីតាមកាលកំណត់ ការកំណត់រយៈពេលអតិបរមានៃសុពលភាព និងការចែងពីកាលបរិច្ឆេទផុតកំណត់ដោយស្វ័យប្រវត្តិ នៅពេលមិនមានចេញសេចក្តីសម្រេចផ្ទុយពីនេះទេនោះ ពាក្យពេជន៍នៃមាត្រា១៦ នេះ នឹងមានប្រសិទ្ធភាពផ្ទុយគ្នា។ ចំនុចនេះកាន់តែក្លាយជាបញ្ហា ប្រសិនបើពិចារណាទៅលើអវត្តមាននៃលក្ខខណ្ឌតម្រូវសម្រាប់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការចេញសេចក្តីសម្រេចនៅមុនពេលផុតកំណត់នៃអនុស្សរណៈបច្ចុប្បន្ន បើទោះបីជាសំណើសុំបន្តសុពលភាពត្រូវបានដាក់ទាន់ពេលវេលាក៏ដោយ។*

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា មាត្រា១៦ គួរធ្វើវិសោធនកម្មដើម្បីអាចឲ្យអនុស្សរណៈមានសុពលភាពសម្រាប់ថិរវេលាមិនកំណត់មួយ លើកលែងតែមានចែងពិសេសផ្សេងពីនេះនៅក្នុងអនុស្សរណៈនោះ ដោយអនុញ្ញាតឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ផ្តួចផ្តើមពិនិត្យឡើងវិញនូវអនុស្សរណៈរបស់ខ្លួនជាមួយនឹងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស នៅពេលណាមួយក៏បាន ប្រសិនបើក្រសួងមានហេតុផលច្បាស់លាស់ និងជាក់លាក់ ដែលជឿថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស កំពុងចូលរួមក្នុងសកម្មភាពខុសច្បាប់។ ក្នុងករណីនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គួរតែផ្តួចផ្តើមចាត់ការតាមនីតិវិធីតុលាការដើម្បីបញ្ចប់អនុស្សរណៈនេះ។*

# ជំពូក៤
# ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា១៨៖**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគមក្នុងស្រុក មានដូចខាងក្រោម៖

- ភាគទាន ឬវិភាគទាន ឬបរិវិសទានរបស់សមាជិក
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត។

ធនធាន និងទ្រព្យសម្បត្តិរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានដូចខាងក្រោម៖

- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់អង្គការ
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត។

**មាត្រា១៩៖**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវបានមកពីប្រភពស្របច្បាប់នានា។

**អនុសាសន៍៖**

*សេចក្តីត្រូវការឲ្យមានការសង្កត់ធ្ងន់នៅក្នុងមាត្រា១៨ និងមាត្រា១៩ គឺធនធាន និងទ្រព្យសម្បត្តិរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវតែបានមកពីប្រភពស្របច្បាប់ គឺជាបញ្ហាដែលត្រូវចោទឡើង ដោយហេតុថា តាមរយៈនិយមន័យមិនមានច្បាប់ណាមួយដែលអនុញ្ញាតឲ្យបុគ្គលឬអង្គការណាមួយ ទទួលនិងប្រើប្រាស់មូលនិធិពីប្រភព មិនស្របច្បាប់នោះឡើយ។* SRFAA *បានអំពាវនាវឲ្យរដ្ឋទាំងឡាយធានាថា "សមាគមដែលបានចុះបញ្ជី និងមិនទាន់បានចុះបញ្ជី អាចស្វែងរក ទទួល និងប្រើប្រាស់មូលនិធិ និងធនធានផ្សេងទៀត ពីរូបវន្តបុគ្គល និងនីតិបុគ្គល ទោះបីជានៅក្នុងស្រុក នៅបរទេស ឬអន្តរជាតិក៏ដោយ ដោយពុំចាំបាច់ត្រូវមានការអនុញ្ញាតជាមុន ឬការបង្អាក់ហួសហេតុផ្សេងទៀត រាប់ទាំងពីបុគ្គល សមាគម មូលនិធិ ឬអង្គការសង្គមស៊ីវិលផ្សេង*

*ទៀត រដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយបរទេស វិស័យឯកជន អង្គការសហប្រជាជាតិ និងអង្គភាពផ្សេងៗទៀត” និងថា “ការរឹតត្បិតហួសហេតុដល់មូលនិធិ រួមទាំងការកំណត់ភាគរយ គឺជាការរំលោភលើសិទ្ធិសេរីភាពនៃការបង្កើតសមាគម និងរំលោភលើលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងៗទៀត រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។”*[34]

ការិយាល័យ OHCHR សូមស្វាគមន៍ការដកចេញនូវការកំណត់ភាគរយទៅលើការប្រើប្រាស់មូលនិធិដោយអង្គការមិនមែនរដ្ឋាភិបាល ដែលមានចែងនៅក្នុងសេចក្តីព្រាងពីលើកមុនៗ និងសូមផ្តល់អនុសាសន៍ឲ្យមានការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវអនុសាសន៍នានាដែលបានរៀបរាប់ខាងលើរបស់ SRFAA។

[34] A/HRC/23/39 កថាខណ្ឌទី៨២(ខ) និង(គ)

# ជំពូក៥
# សិទ្ធិ ផលប្រយោជន៍ និងភាតព្វកិច្ចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា២០៖**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ ត្រូវស្ថិតក្រោមនីតិរូបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២១៖**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ មានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តគម្រោងសកម្មភាព ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២២៖**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ មានសិទ្ធិជ្រើសរើសបុគ្គលិក ឬកម្មករដើម្បីបម្រើការងារ។ ការជ្រើសរើសនេះ ត្រូវអនុវត្តតាមច្បាប់ស្ដីពីអន្តោប្រវេសន៍ ច្បាប់ស្ដីពីការងារ និងលិខិតបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា។

**អនុសាសន៍៖**

*ជំពូក៥ តម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ស្ថិតនៅក្រោមរបបនៃការចុះបញ្ជីជាកាតព្វកិច្ច ជំនួសឲ្យរបបនៃការជូនដំណឹងដែលជាជម្រើសពេញចិត្តមួយតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិទៅវិញ ខណៈដែលជំពូកនេះ មិនបានបង្ហាញពីអត្ថប្រយោជន៍ជាក់លាក់ណាមួយសម្រាប់អង្គការទាំងនោះ ដែលបានចុះបញ្ជី ឬបានចុះអនុស្សរណៈរួចហើយឡើយ ដែលមិនធ្លាប់មានចែងពីមុនមកក្នុងច្បាប់ផ្សេងៗទៀត។ មាត្រា២០-២២ គ្រាន់តែលើកឡើងវិញនូវគោលការណ៍គ្រឹះនៃប្រព័ន្ធច្បាប់ស៊ីវិល ដែលថានីតិបុគ្គលណាមួយ អាចចុះកិច្ចសន្យាដោយស្របច្បាប់ជាមួយទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ទោះបីជាសម្រាប់ការជ្រើសរើសបុគ្គលិកឬគោលបំណងស្របច្បាប់ផ្សេងទៀត។ ចំនុចនេះលើកឡើងជាចម្ងល់នានា ចំពោះសេចក្ដីត្រូវការនៃច្បាប់នេះ នូវទស្សនៈធ្វើឲ្យក្របខ័ណ្ឌច្បាប់ដែលមានស្រាប់កាន់តែទូលំទូលាយជាងនេះ ជាពិសេសក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងច្បាប់ស្ដីពីការប្រឆាំងនឹងអំពើពុករលួយ និងការអនុវត្តនូវច្បាប់ទាំងនោះ។*

*ផ្ទុយទៅវិញ មាត្រា២១ រឹតត្បិតសិទ្ធិសេរីភាពនៃការបង្កើតសមាគមដល់អង្គការដែលបានចុះបញ្ជី ដោយកំណត់លទ្ធភាពក្នុងការចុះកិច្ចសន្យាផ្តល់មូលនិធិ ឬធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តសកម្មភាពនានា ដែលផ្តល់មូលនិធិដោយកិច្ចព្រមព្រៀងទាំងនោះ ឬតាមរយៈ)ធនធានស្របច្បាប់ណាមួយ ដែលមិនមែនជាប់ពាក់ព័ន្ធនឹងកិច្ចសន្យា(ដល់តែអង្គការដែលត្រូវបានចុះបញ្ជី ឬបានចុះអនុស្សរណៈប៉ុណ្ណោះ។ ការរិតត្បិតជាទូទៅបែបនេះ ចំពោះតែអង្គការដែលបានចុះបញ្ជី ឬអនុស្សរណៈ គឺមិនស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ ហើយការរិតត្បិតបែបនេះ មិនត្រូវបានលើកទឹកចិត្តឲ្យមានទាល់តែសោះ ដោយយន្តការសិទ្ធិមនុស្ស (សូមមើលមតិយោបល់ និងអនុសាសន៍នានារបស់ការិយាល័យ OHCHR លើមាត្រា៦ និងមាត្រា៩)។*

**មាត្រា២៤៖**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេស ត្រូវប្រកាន់ជំហរអព្យាក្រិតចំពោះគ្រប់គណៈបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

**អនុសាសន៍៖**

*សេរីភាពក្នុងការបង្កើតសមាគម សេរីភាពនៃគំនិត និងការសម្តែងមតិ សេរីភាពក្នុងការគិត សតិសម្បជញ្ញៈ និងជំនឿសាសនានិងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលបង្កើតបានជាផ្នែកមួយដ៏សំខាន់ នៃគ្រឹះលទ្ធិប្រជាធិបតេយ្យ។ សិទ្ធិទាំងនេះមានចំណងទាក់ទង និងពឹងពាក់គ្នាទៅវិញទៅមក ហើយត្រូវបានបង្កើតឡើងក្រោមរដ្ឋធម្មនុញ្ញកម្ពុជា*[35] *ក៏ដូចជានៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនដែលកម្ពុជាជារដ្ឋភាគីផងដែរ។*

*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ចែងពីសិទ្ធិទាំងនេះសម្រាប់មនុស្សគ្រប់រូប។ មាត្រា១៩ កថាខណ្ឌទី២ ចែងថា មនុស្សគ្រប់រូបមាន "សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល*

---

[35] មាត្រា៣១ ៣៥ ៤១-៤៣ នៃរដ្ឋធម្មនុញ្ញ។ ត្រឹមមាត្រា៤១ ការរឹតត្បិតដែលអនុញ្ញាតស្របតាមរដ្ឋធម្មនុញ្ញ លើការអនុវត្តសេរីភាពសម្តែងមតិ គឺមានតែការសម្តែងមតិទាំងឡាយដែលមានបំណងរំលោភលើសិទ្ធិរបស់អ្នកដទៃ ប៉ះពាល់ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិប៉ុណ្ណោះ។

និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន...” បើយោង តាមគណៈកម្មាធិការសិទ្ធិមនុស្សរបស់អ.ស.ប “សិទ្ធិនេះ រាប់ទាំងការសំដែងមតិ និងការ ទទួលប្រាស្រ័យទាក់ទងតាមគ្រប់រូបភាពនៃគំនិត និងយោបល់ដែលអាចបញ្ជូនបន្តទៅ អ្នកដទៃទៀត... សិទ្ធិនេះ រាប់ទាំងសន្ទរកថានយោបាយ និងពាក្យអត្ថាធិប្បាយអំពីគំនិត របស់ខ្លួនផ្ទាល់ និងអំពីកិច្ចការសាធារណៈ ... (និង (កិច្ចពិភាក្សាអំពីសិទ្ធិមនុស្ស... វិសាលភាពនៃកថាខណ្ឌ២ គ្រប់ដណ្ដប់ទាំងលើការបញ្ចេញមតិដែលអាចចាត់ទុកថាជា ពាក្យសំដីវាយប្រហារធ្ងន់ៗ”[36]។ ការរឹតត្បិតដែលត្រូវបានអនុញ្ញាតិទៅលើការអនុវត្តសិទ្ធិ ទាំងនេះ គឺមានតែសិទ្ធិទាំងឡាយដែលមានកំណត់នៅក្នុងមាត្រា១៩ កឋាខណ្ឌទី៣ និង មាត្រា២០ប៉ុណ្ណោះៗ[37] លើសពីនេះ គណៈកម្មាធិការសិទ្ធិមនុស្ស បង្ហាញទស្សនៈថា “ក្នុង ឱកាសនៃការជជែកដេញដោលជាសាធារណៈ អំពីឥស្សរជនសាធារណៈ ក្នុងវិស័យ នយោបាយ និងស្ថាប័នសាធារណៈ កតិកាសញ្ញានេះ បានឲ្យតម្លៃខ្ពស់ជាពិសេសទៅលើ ការបញ្ចេញមតិដោយសេរី”ៗ[38] គណៈកម្មាធិការសិទ្ធិមនុស្ស សង្កេតឃើញផងដែរថា ប្រជាពលរដ្ឋចូលរួមចំណែកដឹកនាំកិច្ចការសាធារណៈ ដែលជាសិទ្ធិមួយចែងតាមមាត្រា ២៥ នៃ ICCPR ដោយខិតខំប្រឹងប្រែងប្រើប្រាស់ឥទ្ធិពលតាមរយៈការជជែកដេញដោល ជាសាធារណៈ និងកិច្ចពិភាក្សាជាមួយតំណាងរបស់ខ្លួន ឬតាមរយៈសមត្ថភាពរបស់ខ្លួន ដើម្បីរៀបចំខ្លួនឯង។ សិទ្ធិសេរីភាពបង្កើតសមាគម រាប់ទាំងសិទ្ធិក្នុងការបង្កើតនិងចូលរួម អង្គការ និងសមាគមសាមី ជាមួយនឹងកិច្ចការនយោបាយ និងសាធារណៈ គឺសំខាន់ បន្ថែមលើសិទ្ធិទាំងឡាយដែលការពារដោយមាត្រា២៥ៗ[39]

ការរិតត្បិតដែលមានចែងក្នុងមាត្រា២៤ នៃច្បាប់នេះ បានបំពានលើសេរីភាពនៃការ សម្តែងមតិ និងសិទ្ធិមនុស្សផ្សេងទៀត ហេតុដូច្នេះ មិនត្រូវបានអនុញ្ញាតឡើយ ក្រោម ច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

---

[36] សេចក្តីពន្យល់ទូទៅលេខ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស CCPR/C/GC/34 កថាខណ្ឌទី១១។

[37] សូមមើលអនុសាសន៍របស់ការិយាល័យOHCHR លើមាត្រា៨ (មូលហេតុនៃកាបដិសេធ)។ ការដាក់កម្រិតព្រំដែនដែលអនុញ្ញាតចំពោះមាត្រា១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដូចមានចែងក្នុងកថាខណ្ឌទី៣ និងចំពោះមាត្រា២០ គឺមានភាពស្រដៀងគ្នានឹង មាត្រាដែលបានរៀបរាប់ក្នុងអនុសាសន៍លើមាត្រា២២។

[38] CCPR/C/GC/34 កថាខណ្ឌទី៣៨។

[39] សេចក្តីពន្យល់ទូទៅលេខ២៥ របស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប CCPR/C/21/Rev.1/Add.7 កថាខណ្ឌទី៨ និងទី២៦។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា គួរតែដកចេញនូវមាត្រា២៤ នេះ។*

**មាត្រា២៥៖**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវផ្ញើទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ មិនឲ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់។ ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយ ក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន១(មួយ)ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំ។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចស្នើសុំរបាយការណ៍ស្តីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាគម។

អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ចម្លងពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងគ្រប់ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន១(មួយ)ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងចេញពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។

ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**អនុសាសន៍៖**

*<u>បន្ទុកធ្វើរបាយការណ៍</u>៖ មាត្រា២៥ ណែនាំលក្ខខណ្ឌតម្រូវជាច្រើន ក្នុងការធ្វើរបាយការណ៍ ដែលផ្ទុយនឹងលក្ខខណ្ឌតម្រូវតិចតួច ដែលមានចែងក្នុងមាត្រា៥៥ នៃក្រមរដ្ឋប្បវេណី ដែលចែងថា នីតិបុគ្គល ត្រូវធ្វើ និងបន្តធ្វើបច្ចុប្បន្នភាពលើបញ្ជីទ្រព្យសម្បត្តិ និង*

បញ្ជីរាយនាមសមាជិកហើយរក្សាទុកបញ្ជីទាំងពីរនេះនៅទីស្នាក់ការកណ្ដាលរបស់ខ្លួន។[40] ផ្ទុយពីនេះ មាត្រា២៥ នៃច្បាប់នេះ តម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលធ្វើរបាយការណ៍ប្រចាំឆ្នាំ ទៅក្រសួងមហាផ្ទៃ ឬក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ហើយសម្រាប់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណាដែលទទួលបានមូលនិធិពីម្ចាស់ជំនួយ មាត្រា២៥ នេះ តម្រូវបន្ថែមឲ្យអង្គការមិនមែនរដ្ឋាភិបាលទាំងនេះរាយការណ៍ទៅក្រសួងដាក់លាក់ស្ដីពីកិច្ចព្រមព្រៀងផ្ដល់មូលនិធិទាំងអស់ជាមួយម្ចាស់ជំនួយ និងចែករំលែករបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុទាំងអស់ដែលបានដាក់ជូនម្ចាស់ជំនួយ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីមានការយល់ព្រមពី ឬផ្ញើទៅម្ចាស់ជំនួយ។ ករណីអង្គការនានាត្រូវបានតម្រូវរួចហើយឲ្យដាក់របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនទៅរដ្ឋាភិបាល យុត្តិកម្មក្នុងការទាមទារសំណៅចម្លងនៃឯកសារដែលទាក់ទងនឹងម្ចាស់ជំនួយទាំងអស់នេះ គឺមានភាពមិនច្បាស់លាស់សោះ។

ក្នុងសេចក្ដីសម្រេចរបស់ខ្លួនលេខ២២/៦ ស្ដីពី "កិច្ចការពារអ្នកការពារសិទ្ធិមនុស្ស" ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប បានអំពាវនាវដល់រដ្ឋទាំងឡាយ ធានាឲ្យបានថា លក្ខខណ្ឌតម្រូវក្នុងការធ្វើរបាយការណ៍ "មិនរារាំងស្វ័យភាពប្រព្រឹត្តិទៅ [នៃសមាគម]" និង "មិនដាក់ការរឹតត្បិតដោយរើសអើងលើប្រភពមូលនិធិសក្ដានុពលក្នុងគោលបំណងដើម្បីគាំទ្រដល់ការងាររបស់អ្នកការពារសិទ្ធិមនុស្សឡើយផ្សេង...ពីការរិតត្បិតទាំងឡាយ ដែលដាក់ចេញជាធម្មតា ចំពោះសកម្មភាពណាមួយផ្សេងទៀត ដែលមិនទាក់ទងនឹងសិទ្ធិមនុស្សនៅក្នុងប្រទេស ដើម្បីធានាឲ្យបាននូវតម្លាភាព និងគណនេយ្យភាព។"[41] ដោយរួមបញ្ចូលជាមួយមាត្រា៣០ នៃច្បាប់នេះ បទប្បញ្ញត្តិនៃមាត្រា២៥ ដាក់កំហិតលើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ហួសពីការដាក់កំហិតដែលអនុញ្ញាតក្រោមមាត្រា២២(២) នៃ ICPPR។

---

[40] មាត្រា៥៥ នៃក្រមរដ្ឋប្បវេណី "បញ្ជីទ្រព្យសម្បត្តិ និងបញ្ជីរាយនាមសមាជិក៖ (១) នៅពេលបង្កើត និងក្នុងអំឡុងពេលបីខែនៃដើមឆ្នាំអនុវត្តកិច្ចការ នីតិបុគ្គលត្រូវធ្វើបញ្ជីទ្រព្យសម្បត្តិ ហើយត្រូវទុកបញ្ជីនោះនៅក្នុងទីស្នាក់ការជានិច្ច។ (២) នីតិបុគ្គលសាជីវកម្មត្រូវធ្វើបញ្ជីរាយនាមសមាជិក និងទុកនៅទីស្នាក់ការជានិច្ច ហើយរាល់ពេលមានការផ្លាស់ប្ដូរសមាជិក ត្រូវកែតម្រូវបញ្ជីនោះ។"

[41] A/HRC/RES/22/6 កថាខណ្ឌទី៩ កថាខណ្ឌ(ក) និង(ខ)។

ការិយាល័យ OHCHR សូមផ្ដល់អនុសាសន៍ថា មាត្រា២៥ គួរត្រូវបានពិចារណាឡើងវិញ ដើម្បីសម្រាលលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ និងដើម្បីធានាថា លក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ទាំងនោះ បន្តផលប្រយោជន៍ស្របច្បាប់ និងចាំបាច់ត្រូវតែមាននៅក្នុងសង្គមប្រជាធិបតេយ្យមួយ។ លក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលបានបែងចែកតាមកម្រិតផ្សេងៗគ្នា ដែលអាចលើកលែងអង្គការតូចៗមិនឲ្យធ្វើរបាយការណ៍ ឬជំនួសមកវិញ ធ្វើឲ្យមានភាពងាយស្រួលនូវកាតព្វកិច្ចធ្វើរបាយការណ៍របស់ពួកគេ គួរតែយកទៅពិចារណា។ ការធ្វើរបាយការណ៍បន្ថែម អាចតម្រូវសម្រាប់អង្គការធំៗដែលទទួលបានអត្ថប្រយោជន៍ពន្ធច្រើនឬមូលនិធិសាធារណៈ។

<u>ឆន្ទានុសិទ្ធិដ៏ទូលំទូលាយ៖</u> បន្ថែមលើលក្ខខណ្ឌតម្រូវឲ្យធ្វើរបាយការណ៍ដែលត្រូវមានព័ត៌មានច្រើនសន្ធឹកសន្ធាប់ និងលម្អិត សម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលបានរៀបរាប់ខាងលើ មាត្រា២៥ អនុញ្ញាតិ "ក្នុងករណីចាំបាច់" ឲ្យសមាគមត្រូវផ្ដល់សំណៅចម្លងនៃរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេដល់ក្រសួងមហាផ្ទៃ ហើយត្រូវធ្វើការត្រួតពិនិត្យនិងសវនកម្មដោយរដ្ឋាភិបាល។ ដូច្នេះមាត្រា២៥ផ្ដល់ដល់រដ្ឋាភិបាលនូវឆន្ទានុសិទ្ធិដ៏ទូលំទូលាយដើម្បីកំណត់មូលដ្ឋានដែលសមាគមត្រូវបានតម្រូវឲ្យចេញរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ ហើយដែលសមាគម និងអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវធ្វើសវនកម្មដោយរដ្ឋាភិបាល។ SRFAA បានទទួលស្គាល់សិទ្ធិរបស់ស្ថាប័នឯករាជ្យនានាក្នុងការពិនិត្យមើលកំណត់ត្រារបស់សមាគម ថាជាយន្តការមួយដើម្បីធានាឲ្យមានតម្លាភាព និងគណនេយ្យភាព ដោយគ្រប់ពេលទាំងអស់ត្រូវសង្កត់ធ្ងន់ថា វាត្រូវតែជាស្ថាប័នឯករាជ្យដែលធ្វើការងារបែបនេះ ថានីតិវិធីដូចនេះមិនគួរត្រូវបានបំពាន ហើយថាវាត្រូវតែគោរពតាមគោលការណ៍មិនរើសអើង និងសិទ្ធិឯកជន បើមិនដូច្នេះទេ វាអាចបង្កឲ្យមានហានិភ័យដល់ឯករាជ្យភាពរបស់សមាគម និងសុវត្ថិភាពនៃសមាជិករបស់ពួកគេ។[42]

[42] A/HRC/20/27 កថាខណ្ឌទី៦៥។

ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ឲ្យមានការផ្លាស់ប្តូរឃ្លា "ក្នុងករណីចាំបាច់" ដោយភាសាជាក់លាក់ ដែលកំណត់ករណីទាំងឡាយដែលសមាគមអាចតម្រូវឲ្យចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ឬសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចត្រូវបានធ្វើសវនកម្មដោយរដ្ឋាភិបាល ចំពោះករណីទាំងនោះដែលមានហេតុផលសង្ស័យថា បទល្មើសមួយត្រូវបានប្រព្រឹត្ត។

# ជំពូកទី៦
## ការផ្អាកសកម្មភាព ការរំលាយ ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

មាត្រា២៦៖

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចផ្អាកសកម្មភាពរបស់ខ្លួន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ។ មុននឹងផ្អាកសកម្មភាព សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា២៥ នៃច្បាប់នេះ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មុននឹងរំលាយ ត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន។

**អនុសាសន៍៖**

*មាត្រា២៦ មិនស្របនឹងមាត្រា២៥ កថាខណ្ឌទី១ ដែលសំដៅតែទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនសំដៅលើសមាគមក្នុងស្រុក។*

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា ហេតុផលនានាលើភាពខុសគ្នាចំពោះការប្រព្រឹត្តិទៅលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គួរតែបញ្ជាក់ឲ្យច្បាស់ជាងនេះ។*

មាត្រា២៩៖

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានរំលាយ ដោយសេចក្តីសម្រេចរបស់តុលាការ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីដោយសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ការជម្រះកាតព្វកិច្ច ព្រមទាំងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលត្រូវបានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រេចបញ្ចប់សុពលភាពអនុស្សរណៈមុនកាលកំណត់ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានស្នើសុំបើកទីស្នាក់ការតំណាងនៅព្រះរាជាណាចក្រកម្ពុជា។

**អនុសាសន៍៖**

*កថាខណ្ឌទី១ នៃមាត្រា២៩ មានភាពមិនច្បាស់លាស់អំពីរបៀបដែលធនធាន និងទ្រព្យសម្បត្តិនឹងត្រូវចាត់ចែង នៅពេលដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវបានលុបឈ្មោះចេញពីបញ្ជីរបស់ក្រសួងមហាផ្ទៃ ដោយមិនមានសេចក្តីសម្រេចណាមួយពីតុលាការ (ទោះបីជាអនុសាសន៍របស់ការិយាល័យ*OHCHR *លើមាត្រា៣០ ថាការកំណត់ណាមួយដែលនាំឲ្យមានការលុបឈ្មោះចេញពីបញ្ជីគួរជាបញ្ហាចោទចំពោះតែតុលាការ*)

# ជំពូកទី ៧
# វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

**អនុសាសន៍៖**

*បទប្បញ្ញត្តិនៃជំពូកទី៧ បំពានលើគោលការណ៍ដែលការចុះបញ្ជីមិនគួរជាកាតព្វកិច្ចទេ ប៉ុន្តែជាការស្ម័គ្រចិត្ត។ ដោយប្រគល់សិទ្ធិអំណាចដល់ក្រសួងមហាផ្ទៃ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដាក់ទណ្ឌកម្មលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលតាមរយៈការលុបឈ្មោះចេញពីបញ្ជី(មាត្រាទី៣០និង៣៣) ការពិន័យ(មាត្រា៣២) និងការបណ្តេញចេញនូវជនបរទេស (មាត្រា៣៤) បទប្បញ្ញត្តិទាំងនេះក៏បំពានផងដែរលើទស្សនៈរបស់ SRHRD ដែលថា មានតែប្រព័ន្ធតុលាការឯករាជ្យតែមួយគត់ គួរមានសិទ្ធិអំណាចដាក់ទណ្ឌកម្មលើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលគួរតែអាចធ្វើទៅបានពាក់ព័ន្ធតែទៅនឹងការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មមួយ ទោះបីជាទង្វើរំលោភបំពានផ្នែករដ្ឋបាល ដូចជាការខកខានមិនបានដាក់របាយការណ៍សកម្មភាពគួរត្រូវដោះស្រាយតាមរយៈនីតិវិធីរដ្ឋបាលក៏ដោយ។ "ភាពមិនប្រក្រតីផ្នែករដ្ឋបាល ... មិនគួរត្រូវចាត់ទុកថាជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការបិទអង្គការមួយទាល់តែសោះ។"[43]*

SRHRD*បានសង្កត់ធ្ងន់ជាពិសេសថា៖"អាជ្ញាធររដ្ឋាភិបាលគួរតែមិនត្រូវបានផ្តល់អំណាចក្នុងការផ្អាកដោយបំពាននូវសកម្មភាពរបស់ក្រុមសិទ្ធិមនុស្សឡើយ។ មានតែតុលាការមួយគត់ដែលគួរតែមានសិទ្ធិបញ្ជាឲ្យផ្អាក ហើយការផ្អាកនេះធ្វើឡើងតែនៅក្នុងស្ថានភាពដែលមានគ្រោះថ្នាក់ច្បាស់លាស់ និងដែលនឹងកើតឡើងឆាប់ៗដែលអាចបណ្តាលដោយផ្ទាល់មកពីសកម្មភាពបែបនេះ និងដែលត្រូវបានរកឃើញដោយសត្យានុម័ត"។[44] សូមរំលឹកថា មនុស្សគ្រប់រូបរស់នៅក្នុងប្រទេសកម្ពុជា -ជនជាតិខ្មែរ ក៏ដូចជាជនបរទេសដែរ - គឺស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជារួចទៅហើយ ហើយការរំលោភច្បាប់ព្រហ្មទណ្ឌកម្ពុជានេះអាចបង្កើតបានដោយស្របច្បាប់នូវមូលដ្ឋាននៃការព្យួរ ឬលុបឈ្មោះសមាគម*

---

[43] A/59/401 កថាខណ្ឌទី ៨២ (ច)។

[44] A/59/401 កថាខណ្ឌទី ៨២ (ទ)

*ឬអង្គការមិនមែនរដ្ឋាភិបាល ទោះជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬបរទេសក៏ដោយ។ អំពើឧក្រិដ្ឋគួរតែត្រូវបានកំណត់ និងដាក់ពិន័យដោយតុលាការឯករាជ្យ ដូចដែលមាននៅក្នុងមាត្រា៣៦។*

**មាត្រា៣០៖**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តតាមមាត្រា១០ ឬមាត្រា២៤ ឬកថាខណ្ឌទី១ ឬកថាខណ្ឌទី២ នៃមាត្រា២៥ នៃច្បាប់នេះ ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីមិនអនុវត្តតាមការជូនដំណឹង ក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជាបណ្តោះអាសន្នរយៈពេលយ៉ាងយូរ ៩០(កៅសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខន្តិកៈរបស់ខ្លួន ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬផ្អាកសកម្មភាពជាបណ្តោះអាសន្នដោយទុកពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃត្រូវតែសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។

ក្រសួងមហាផ្ទៃ ត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**អនុសាសន៍៖**

*យោងតាមអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម (SRFAA) សិទ្ធិសេរីភាពក្នុងការបង្កើតសមាគមនេះអនុវត្តបានពេញមួយជីវិតរបស់សមាគម។ ការព្យួរ និងការរំលាយដោយមិនស្ម័គ្រចិត្តនូវសមាគមទាំងនោះ គឺជាប្រភេទនៃការរឹតត្បិតដ៏តឹងតែងបំផុតដល់សេរីភាពក្នុងការបង្កើតសមាគម។ "វាគួរតែអាចធ្វើទៅបានតែនៅពេលដែលមានគ្រោះថ្នាក់ច្បាស់លាស់ និងដែលនឹងកើតឡើងឆាប់ៗដែលបណ្តាលឲ្យមានការរំលោភដាក់ស្តែងលើច្បាប់ជាតិដោយអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ វាគួរតែសមាមាត្រយ៉ាងដាច់ខាតទៅនឹងគោលបំណងស្របច្បាប់ដែលបន្តសម្រេចឲ្យបាន និងប្រើប្រាស់តែនៅពេលដែលវិធាន*

*ការទន់ភ្ជន់មិនមានគ្រប់គ្រាន់។"[45] អ្នករាយការណ៍ពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្ស (SRHRD) បានថ្លែងថា ការរឹតត្បិតដោយផ្អែកលើមូលដ្ឋាននៃ "សណ្តាប់ធ្នាប់សាធារណៈ/សីលធម៌/ក្រមសីលធម៌" និងលក្ខណៈវិនិច្ឆ័យណាមួយដែលសំដៅដល់ការកម្រិតសិទ្ធិជួបប្រជុំដោយសេរី ត្រូវតែកំណត់ឲ្យបានច្បាស់ និងថាសកម្មភាពដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សត្រូវតែដកចេញពីការរឹតត្បិតទាំងនេះ។[46] មូលដ្ឋានមួយចំនួនក្នុងការលុបឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលចេញពីបញ្ជី មិនជម្រះឲ្យដាច់ស្រឡះនូវកម្រិតនៃ "គ្រោះថ្នាក់ច្បាស់លាស់ និងដែលនឹងកើតឡើងឆាប់ៗ" ឡើយ។*

*ការិយាល័យ OHCHR សម្តែងការព្រួយបារម្ភរបស់ខ្លួនជាថ្មីម្តងទៀត លើមាត្រា២៨ និង ២៩ នៃច្បាប់នេះ (សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រាទាំងនោះ) និងសម្តែងការព្រួយបារម្ភថា មាត្រាទាំងនោះគួរតែបង្កើតមូលដ្ឋាននានា ស្របតាមមាត្រា៣០ ក្នុងការផ្អាក ឬលុបឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ លើសពីនេះទៀត ការប្រើប្រាស់ពាក្យនៅក្នុងមាត្រា៣០ នឹងអនុញ្ញាតឲ្យក្រសួងផ្អាកសកម្មភាព ឬលុបឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចេញពីបញ្ជី ចំពោះការខកខានមិនបានគោរពតាមលក្ខន្តិកៈរបស់ខ្លួនផ្ទាល់ សូម្បីតែនៅពេលការខកខានបែបនេះមិនបង្កើតជាបទល្មើសនៅក្រោមច្បាប់កម្ពុជាក៏ដោយ។*

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា ជំពូកទី៧ គួរតែត្រូវបានតាក់តែងឡើងវិញ ដើម្បីផ្តល់សិទ្ធិអំណាចឲ្យតែប្រព័ន្ធតុលាការ ក្នុងការដាក់ទណ្ឌកម្មលើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ចំពោះការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ និងបង្កើតនីតិវិធីរដ្ឋបាលដើម្បីដោះស្រាយអំពើល្មើសខាងផ្នែករដ្ឋបាល។*

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា មាត្រា៣០ និង៣៦ គួរតែតាក់តែងឡើងវិញដោយរួមបញ្ចូលគ្នាដូចតទៅ៖ "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលសង្ស័យថាបានរំលោភលើច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជា នឹងត្រូវធ្វើការស៊ើបអង្កេតដោយតុលាការ ដែលអាចឈានទៅដល់ការចេញដីកាពីតុលាការដើម្បី*

---

[45] A/HRC/20/27 កថាខណ្ឌទី៧៥។

[46] A/59/401 កថាខណ្ឌទី៨២(ណ)។

*ផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងនោះ រយៈពេលរហូតដល់ទៅ ៣០(សាមសិប)ថ្ងៃ ដោយត្រូវរង់ចាំសាលក្រមពីតុលាការ។ ក្នុងសាលក្រមរបស់ខ្លួន តុលាការអាចបញ្ជាឲ្យលុបឈ្មោះសមាគម ឬអង្គការនោះចេញពីបញ្ជី"។*

មាត្រា៣១៖

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជី ការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការពិន័យទៅតុលាការ ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេច។

**អនុសាសន៍៖**

*ច្បាប់ជាតិដែលនៅជាធរមាននៅឡើយ ចែងថា រាល់ភាគីនៃបណ្តឹងវិវាទមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍។ ប្រសិនបើមាត្រា២៨, ២៩, ៣០, ៣២, ៣៣ និង៣៦ ត្រូវបានធ្វើវិសោធនកម្មដើម្បីឲ្យអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនោះ បទប្បញ្ញត្តិនេះនឹងជាន់គ្នា ហើយការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា គួរតែលុបចោលមាត្រា៣១ ឬជម្រើសផ្ទុយពីនេះ គួរបញ្ចូលមាត្រា៣១ នេះ នូវសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃតាមរយៈសាលាឧទ្ធរណ៍។*

មាត្រា៣២៖

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសកម្មភាពសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ក្នុងករណីមិនរាងចាល សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ដោយក្រសួងមហាផ្ទៃ។ ក្នុងករណីនៅតែបន្តធ្វើសកម្មភាពបន្តទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមច្បាប់ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

បទប្បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាព ហើយនៅតែបន្តធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**អនុសាសន៍៖**

*បន្ថែមលើមតិយោបល់ និងអនុសាសន៍របស់ខ្លួនលើជំពូកទី៧ ទាំងមូល ការិយាល័យ OHCHR សូមផ្ដល់អនុសាសន៍ថា ការពិន័យខាងផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរដែលអាចបានមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានអនុវត្តតាមនោះ គួរតែត្រូវកាត់បន្ថយ និងគួរដាក់ឲ្យស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការឯករាជ្យ មិនមែនអង្គនីតិប្រតិបត្តិឡើយ ក្នុងករណីបទល្មើសព្រហ្មទណ្ឌមួយត្រូវបានគេបង្ហាញថាបានប្រព្រឹត្តនោះ។*

**មាត្រា៣៣៖**

ក្នុងករណីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនបានអនុវត្តតាមមាត្រា១៧ ឬមាត្រា២៤ ឬកថាខណ្ឌទី៣នៃមាត្រា២៥នៃច្បាប់នេះ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។ ក្នុងករណីមិនអនុវត្ត ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយទុករយៈពេល៣០(សាមសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ។

**អនុសាសន៍៖**

*ច្បាប់នេះគួរតែពិចារណាឲ្យមានការព្រមានចំនួនពីរលើក ដោយត្រូវផ្ដល់ពេលវេលាដើម្បីឲ្យអនុវត្តតាម ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ ក្នុងមួយលើកៗ (ដោយមិនត្រូវមានរយៈពេលអប្បបរមាទេ) ហើយបន្ទាប់មក ត្រូវមានវិធានការនានាចាត់ឡើងដើម្បីបិទសមាគម ឬអង្គការ និងនិរទេសកម្មករបរទេស។ ក្នុងករណីមិនមានភ័ស្តុតាងស្ដីពីបទល្មើសព្រហ្មទណ្ឌទេ បើតាមទ្រឹស្ដី គួរតែអនុញ្ញាតឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លុបចោលអនុស្សរណៈ។ អនុស្សរណៈដែលជាមូលដ្ឋានគតិយុត្តិសម្រាប់ប្រតិបត្តិការរបស់អង្គការបរទេសមួយ និងលំនៅដ្ឋានស្របច្បាប់នៅក្នុងប្រទេសកម្ពុជារបស់និយោជិតរបស់ខ្លួនតាមរយៈការអានមាត្រា៣៣ និងមាត្រា៣៤ អនុញ្ញាតឲ្យក្រសួងបិទប្រកបដោយប្រសិទ្ធភាពនូវអង្គការបរទេស ដោយពុំមាននីតិវិធីត្រឹមត្រូវ ឬការត្រួតពិនិត្យដោយឯករាជ្យឡើយ។ ដូចច្នេះហើយ មាត្រា៣៣ នេះ ប្រគល់អំណាចហួសហេតុ*

*ដល់អង្គនីតិប្រតិបត្តិ ធ្វើការជ្រៀតជ្រែកក្នុងប្រតិបត្តិការរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។ (សូមមើលមតិយោបល់របស់ការិយាល័យ* OHCHR *និងអនុសាសន៍លើជំពូក៧ ទាំងមូល។)*

**មាត្រា៣៤៖**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណាដែលធ្វើសកម្មភាពដោយមិនចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ វិធានការបន្ថែមទាក់ទងនឹងការបណ្តេញចេញស្របតាមច្បាប់អន្តោរប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណាដែលបម្រើការងារនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលប្រព្រឹត្តល្មើសខាងលើ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**អនុសាសន៍៖** *សូមមើលមតិយោបល់ និងអនុសាសន៍របស់*OHCHR *លើជំពូកទី៧ទាំងមូល។*

**មាត្រា៣៥៖**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពអនុស្សរណៈក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈដែលចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា។

**អនុសាសន៍៖**

*<u>មូលដ្ឋាននៃការបញ្ចប់អនុស្សរណៈ</u>៖ បញ្ជីនៃបទល្មើសតាមមាត្រានេះដែលអាចបង្ហាញអំពីភាពត្រឹមត្រូវនៃការបញ្ចប់សុពលភាពនៃអនុស្សរណៈ គឺមានលក្ខណៈទូលំទូលាយជាង និងមិនស្របជាមួយនឹងមូលដ្ឋានដែលអនុញ្ញាតចំពោះការរឹតត្បិតលើសិទ្ធិសេរីភាពនៃការបង្កើតសមាគម ដែលមានចែងក្នុង* ICCPR *(សូមមើលអនុសាសន៍របស់* OHCHR *លើមាត្រា៤, ៨, ៣០)។* ***ការិយាល័យ*** **OHCHR** ***សូមផ្តល់អនុសាសន៍ថា មាត្រា៣៥ គួរតែឲ្យស្របនឹងមាត្រា២២ កថាខណ្ឌទី២ នៃ*** **ICCPR នេះ។**

*<u>ការខកខានមិនបានអនុវត្តតាមអនុស្សរណៈឲ្យបានត្រឹមត្រូវ៖</u> ដោយសារតែច្បាប់នេះមិនបានកំណត់អំពីមាតិកានៃអនុស្សរណៈដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស តម្រូវឲ្យចុះនៅក្រសួងការបរទេស និងសហប្រតិបត្តិការនោះ ខណៈនេះ វាមិនអាចធ្វើទៅបានឡើយក្នុងការកំណត់ធាតុផ្សំទាំងឡាយនៃអនុស្សរណៈ ដែលអាចនាំឲ្យមានមោឃភាពនៃអនុស្សរណៈនេះ។ ទោះបីជាយ៉ាងនេះក្តី ការអះអាងជាថ្មីឡើងវិញថា ការបំពានខាងផ្នែករដ្ឋបាល គួរតែដំណើរការក្រោមនីតិវិធីរដ្ឋបាលក្នុងគោលបំណងដើម្បីឲ្យមានវិធានការបង្ការកែតម្រូវជាជាងការបិទសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល (សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើជំពូក៧ ទាំងមូល)។*

ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា មាត្រា៣៥ គួរតែធ្វើវិសោធនកម្មដើម្បីបញ្ជាក់ឲ្យច្បាស់លាស់ថា "ក្នុងករណីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រកឃើញភាពមិនប្រក្រតីផ្នែករដ្ឋបាល ក្នុងការអនុវត្តអនុស្សរណៈ ដែលបានចុះជាមួយសមាគម ឬអង្គការក្រៅរដ្ឋាភិបាលបរទេសមួយ ហើយក្រសួងត្រូវផ្តួចផ្តើមកិច្ចពិភាក្សាមួយជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសសាមី ដើម្បីឲ្យមានការកែតម្រូវនូវភាពមិនប្រក្រតីទាំងនោះ។"

*<u>កិច្ចធានាការពារតាមនីតិវិធី៖</u> មាត្រា៣៥ ខកខានកំណត់កិច្ចធានាការពារតាមនីតិវិធីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អាចប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលខ្លួនចាត់ទុកថាមិនសមហេតុផលនោះ។* ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា គួរដាក់បញ្ចូលឲ្យមានកិច្ចធានាការពារតាមនីតិវិធីជាក់លាក់ រាប់ទាំង នីតិវិធីដើម្បីប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផង។

*<u>"ស្ថិរភាព" និង "ឯកភាពជាតិ"៖</u> សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា៨។*

ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា មាត្រា៣៥ គួរអនុលោមតាមមាត្រា២២ កថាខណ្ឌ២ នៃ ICCPR។

*<u>"វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា"</u>៖ សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា៨។*

***ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា មាត្រា៣៥ គួរអនុលោមតាមមាត្រា២២ កថាខណ្ឌ២ នៃ ICCPR។***

**មាត្រា៣៦៖**

សមាគមឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលសកម្មភាពរបស់ខ្លួនធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**អនុសាសន៍៖**

*មាត្រា៣៦ ទំនងជាជាន់គ្នា។ មាត្រានេះមិនជួយបង្កើននូវការការពារសន្តិសុខជាតិឡើយ ដោយហេតុថាសកម្មភាពទាំងអស់ដែលត្រូវបានកំណត់ និងផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ គឺស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌដែលនៅជាធរមានហើយ និងមានការផ្តន្ទាទោសរួចទៅហើយតាមច្បាប់នេះ ទន្ទឹមនោះ សកម្មភាពទាំងឡាយណាដែលមិនមានចែង នឹងមិនត្រូវបានផ្តន្ទាទោសតាមមាត្រា៣៦ ទៅវិញ។ SRFAA ទទួលស្គាល់ថា៖ "រដ្ឋទាំងឡាយមានការទទួលខុសត្រូវក្នុងការដោះស្រាយការសម្អាតប្រាក់ និងភេរវកម្ម" ប៉ុន្តែបានសង្កត់ធ្ងន់ថា៖ "ចំនុចនេះមិនគួរប្រើជាយុត្តិកម្មមួយ ដើម្បីធ្វើឲ្យថមថយបន្តិចម្តងៗ នូវភាពជឿជាក់របស់សមាគមដែលពាក់ព័ន្ធ និងក៏មិនគួរបន្ទុចបង្អាក់ហួសហេតុពេកនូវការងារស្របច្បាប់របស់សមាគមនោះដែរ។ ដើម្បីធានាថាសមាគមនានា មិនត្រូវបានរំលោភបំពានដោយអង្គការភេរវកម្ម រដ្ឋទាំងឡាយគួរតែប្រើយន្តការផ្សេងជំនួសដើម្បីកាត់បន្ថយហានិភ័យ ដូចជាតាមរយៈច្បាប់ធនាគារ និងច្បាប់ព្រហ្មទណ្ឌដែលហាមឃាត់អំពើភេរវកម្ម។"[47]*

***ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា គួរតែដាក់បញ្ចូលរួមគ្នានូវមាត្រា៣០ និងមាត្រា៣៦ (សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា៣០ និងអនុសាសន៍សម្រាប់ការតាក់តែងឡើងវិញដែលបានស្នើឡើង)។***

[47] A/HRC/20/27 កថាខណ្ឌទី៧០។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៣៧៖**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជី និងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៣៨៖**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគមឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជីស្របតាមច្បាប់នេះ និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ។

**អនុសាសន៍៖**

*ការិយាល័យ OHCHR សូមស្វាគមន៍នូវអវត្តមាននៃលក្ខខណ្ឌតម្រូវចុះបញ្ជីឡើងវិញ។*

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៣៩៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**អនុសាសន៍៖**

*<u>ផ្ទុយនឹងច្បាប់អន្តរជាតិ</u>៖ មាត្រា៣៩ មិនបានពិចារណាទៅលើស្ថានភាពនៃច្បាប់សិទ្ធិមនុស្ស ដែលមានចែងនៅក្នុងសន្ធិសញ្ញានានាដែលកម្ពុជាបានផ្តល់សច្ចាប័ន ក៏ដូចជារដ្ឋធម្មនុញ្ញ និងច្បាប់នានាដែលបានអនុម័តដោយរដ្ឋសភា។ ពាក់ព័ន្ធនឹងសន្ធិសញ្ញានានាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន មាត្រា២៧ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា បានចែងថា "ភាគីមួយមិនអាចលុបចោលវិញនូវបទប្បញ្ញត្តិនៃច្បាប់ផ្ទៃក្នុងរបស់ខ្លួនជាយុត្តិកម្មសម្រាប់ការខកខានមិនបានអនុវត្តសន្ធិសញ្ញារបស់ខ្លួននោះឡើយ។" មាត្រាមួយចំនួននៃច្បាប់នេះ ផ្ទុយនឹងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិសេរីភាពក្នុងការបង្កើត*

សមាគម និងសិទ្ធិសេរីភាពក្នុងការសម្តែងមតិ ដែលចងកាតព្វកិច្ចលើប្រទេសកម្ពុជា ដូចបានពន្យល់នៅក្នុងអនុសាសន៍លើមាត្រាមួយចំនួននោះ។ ដូច្នេះ ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវមាត្រា៣៩ នៃច្បាប់នេះ នឹងនាំឲ្យមានការរំលោភលើច្បាប់អន្តរជាតិ។

ផ្ទុយនឹងច្បាប់ជាតិ៖ មាត្រានេះក៏ចោទជាសំណួរផងដែរ ពាក់ព័ន្ធនឹងស្ថានភាពនៃច្បាប់នេះ ទាក់ទងនឹងច្បាប់ដទៃទៀត ជាពិសេសច្បាប់អង្គការ ដូចជារដ្ឋធម្មនុញ្ញដែលមានចែងអំពីសិទ្ធិមនុស្សជាមូលដ្ឋាន។ ការរំលោភលើច្បាប់អន្តរជាតិដែលឃើញមាននៅក្នុងសេចក្តីព្រាងច្បាប់នេះ ក៏នឹងបង្កើតបានជាការរំលោភរដ្ឋធម្មនុញ្ញកម្ពុជាផងដែរ ជាពិសេសមាត្រា៣១ (សូមមើលសេចក្តីផ្តើមនៃសេចក្តីវិភាគនេះ)។ បញ្ហានីតិវិធីមួយចំនួនដែលបានគ្របដណ្តប់លើច្បាប់នេះ ក៏ផ្ទុយផងដែរនឹងក្រមរដ្ឋប្បវេណី និងច្បាប់ឆ្នាំ២០១១ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ (សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា៦ និងមាត្រា១៤)។

ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ឲ្យមានការពិនិត្យឡើងវិញដ៏ហ្មត់ចត់ ជាសារវន្ត និងដោយមានកិច្ចពិគ្រោះយោបល់លើច្បាប់នេះ ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងសេចក្តីវិភាគនេះដូច្នេះ តាមរយៈនេះ នឹងអាចទប់ស្កាត់ភាពផ្ទុយគ្នាដែលបានសង្ខេបនៅក្នុងអនុសាសន៍ចុងក្រោយនេះ។

***

## ឧបសម្ព័ន្ធ

## ច្បាប់សិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធដែលចងកាតព្វកិច្ចលើប្រទេសកម្ពុជា ដែលចែងពីសេរីភាពក្នុងការបង្កើតសមាគម

- ➢ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា២០ និងមាត្រា២៣)
- ➢ កម្ពុជាជារដ្ឋភាគីនៃសន្ធិសញ្ញាអន្តរជាតិ ដូចខាងក្រោម៖
  - កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា២១ និងមាត្រា២២)
  - កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា៨)
  - អនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា១៥)
  - អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (មាត្រា២៤(៧))
  - អនុសញ្ញាស្តីពីសិទ្ធិជនពិការ (មាត្រា២៩)
  - អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (មាត្រា៧(គ))
  - អនុសញ្ញា និងពិធីសារពាក់ព័ន្ធឋានៈជនភៀសខ្លួន (មាត្រា១៥ នៃអនុសញ្ញា)
  - អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ ស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម (អនុសញ្ញាលេខ៨៧ មាត្រា២);
- ➢ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស (សេចក្តីសម្រេចរបស់មហាសន្និបាតលេខ៥៣/១៤៤(១៩៩៩)) និងសេចក្តីសម្រេចជាបន្តបន្ទាប់លេខ៦៤/១៦៣ (២០០៩))។